ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# លទ្ធផលនៃអង្កេតភពផែនដី

# នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០

## (តំបន់ខ្ពង់រាបក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និង ខេត្តបាត់ដំបង)


រៀបចំដោយ៖

អង្គភាពក្រុមសង្កេតការណ៍ភពផែនដី

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ



ខែ កុម្ភៈ ឆ្នាំ ២០២១

# និមិត្តសញ្ញាសំគាល់
# ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា
( Cambodia GEO )

## មុខកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដោយសូមបង្ហាញជូននូវសមិទ្ធផលថ្មីមួយទៀតដែលសម្រេចបានរបស់ក្រសួងផែនការនៅក្នុងអាណត្តិទី ៦ របស់រាជរដ្ឋាភិបាលកម្ពុជា គឺរបាយការណ៍លទ្ធផលវិភាគទិន្នន័យអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០ ដែលបានសិក្សាទៅលើខេត្ត ៣ នៅតំបន់ខ្ពង់រាបដែលរួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង បើទោះបីស្ថិតនៅក្នុងដំណាក់កាលឆ្លងកាត់ការលំបាកនៃការឆ្លងជំងឺរាតត្បាតកូវីដ ១៩ ក៏ដោយ។ ។ អង្កេតភពផែនដី គឺជាអង្កេតលើកទី ២ ដែលបានដឹកនាំអនុវត្តដោយអង្គភាពក្រុមសង្កេតការណ៍ភពផែនដី ស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បន្ទាប់ពីប្រទេសកម្ពុជាបានចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅឆ្នាំ ២០១៧ រួចមក។

អង្កេតភពផែនដីនេះ គឺបានប្រមូលទិន្នន័យនូវសូចនាករចម្បងៗ ស្តីអំពីស្ថានភាពលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ខ្ពង់រាប នៅក្នុងគោលដៅនៃខេត្តទាំង ៣ ខាងលើ។ វិធីសាស្ត្រនៃការប្រមូលទិន្នន័យនៃអង្កេតនេះ គឺត្រូវបានធ្វើឡើងតាមរយៈការសម្ភាសន៍ប្រធានភូមិ និងមេគ្រួសារនៅក្នុងតំបន់គោលដៅ ខណៈដែលប្រទេសកម្ពុជាយើងពុំទាន់មានផ្កាយរណប និងពុំមានប្រទេសណាមួយជួយផ្តល់នូវទិន្នន័យតាមរយៈផ្កាយរណបនៅឡើយ។ ថវិកាដែលប្រើប្រាស់នៅក្នុងការធ្វើអង្កេតនេះ គឺបានការជួយឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាកម្មវិធីឆ្នាំ ២០២០ របស់ក្រសួងផែនការ ។

ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាវជ្រៅជាទីបំផុត ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព និងការឯកភាពជាតិទូទាំងប្រទេសតាមរយៈគោលនយោបាយ «**ឈ្នះឈ្នះ**» ដែលបានផ្តល់ឱកាសដល់ការងារប្រមូលទិន្នន័យនៅតំបន់គោលដៅប្រកបដោយជោគជ័យ។

ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឯកឧត្តមបណ្ឌិត **ម៉េង គីមហ៊ី** អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងជាប្រធានអង្គភាពក្រុមសង្កេតការណ៍ភពផែនដី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមន្ត្រីពាក់ព័ន្ធទាំងអស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ព្រមទាំងមន្ត្រីថ្នាក់ក្រោមជាតិ ដែលរួមមានមន្ត្រីរបស់មន្ទីរផែនការខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលបានចូលរួមក្នុងការប្រមូលទិន្នន័យតាមតំបន់គោលដៅនៅក្នុងខេត្តទាំង ៣ ខាងលើនេះ។ ខ្ញុំសូមអរគុណចំពោះការខិតខំប្រឹងប្រែង របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចូលរួមសកម្មភាពការងារទាំងអស់នេះ។

ជាចុងក្រោយ ខ្ញុំសូមអរគុណ និងកោតសរសើរដល់អង្គភាពក្រុមសង្កេតការណ៍ភពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានបំពេញការងារយ៉ាងល្អប្រសើរប្រកបដោយវិជ្ជាជីវៈខ្ពស់ ការប្តេជ្ញាចិត្តមោះមុត និងការលះបង់ដ៏ធំធេង ដើម្បីការងារអង្កេតនេះទទួលបានលទ្ធផលគួរជាទីទុកចិត្តដល់គ្រប់អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ ។

ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលកម្ពុជានឹងទទួលបាននូវសារៈប្រយោជន៍ពីលទ្ធផលនៃការធ្វើអង្កេតនេះ ដោយប្រើប្រាស់ទិន្នន័យក្នុងអង្កេតកសិកម្មកពផែនដី ដើម្បីរៀបចំធ្វើផែនការ និងរៀបចំគោលនយោបាយទាក់ទងទៅនឹងការតាមដានត្រួតពិនិត្យលក្ខណៈប្រជាសាស្ត្រ ផ្នែកបរិស្ថាន ការពារគ្រោះមហន្តរាយ និងមានវិធានការណ៍សមស្របទាក់ទងនឹងការប្រែប្រួលអាកាសធាតុ បន្ថែមពីលើទិន្នន័យដែលបានមកពីប្រភពដទៃទៀត ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ អ្នកប្រើប្រាស់ទិន្នន័យទាំងឡាយ ក៏ដូចជាអ្នកស្រាវជ្រាវ អ្នកវិភាគ និងអង្គការក្រៅរដ្ឋាភិបាលនានា ក៏អាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលនៃអង្កេតនេះផងដែរ នៅក្នុងការស្វែងយល់អំពីលក្ខណៈប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់គោលដៅខាងលើ។

ថ្ងៃអង្គារ ៥ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២១

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

របាយការណ៍លទ្ធផលស្ដីពីអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០ នេះបាន ផលិតដោយអង្គភាពក្រុមសង្កេតការណ៍ភពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួង ផែនការ។ ចាប់តាំងពីប្រទេសកម្ពុជាចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការភពផែនដីនៅឆ្នាំ ២០១៧ មក គម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជានេះ បានចុះស្រង់ទិន្នន័យនៅឆ្នាំ ២០១៩ ដែលមានចំនួនខេត្ត៥ ដែលស្ថិតជាប់បឹងទន្លេសាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។ នៅក្នុងឆ្នាំ ២០២០ នេះ ការចុះស្រង់ទិន្នន័យនៅក្នុងតំបន់ខ្ពង់រាប រួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបងបានអនុវត្តនៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០ ដោយទទួលថវិកាឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈថវិកាកម្មវិធីប្រចាំឆ្នាំរបស់ក្រសួងផែនការ ។

គោលបំណងចម្បងនៃអង្កេតនេះគឺដើម្បីប្រមូលនូវសូចនាករសំខាន់ៗទាក់ទងនឹងប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ តាមរយៈការសម្ភាសន៍មេភូមិ និងមេគ្រួសារ ជំនួសឲ្យការទទួលបានទិន្នន័យពីផ្កាយរណប និងឧបករណ៍ថតរូបភាពផ្សេងៗ ដែលថតពីលើអាកាស ខណៈដែលបច្ចុប្បន្នការប្រមូលទិន្នន័យបែបនេះ ពុំទាន់មានលទ្ធភាពធ្វើទៅបាន។ លទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០ នេះ រួមមានរបាយការណ៍លទ្ធផលអង្កេតជាឯកសារបោះពុម្ព និងឯកសារជាអេឡិចត្រូនិក ហើយក៏មានដាក់ចូលនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការទៀតផង។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ដែលបានផ្ដល់អនុសាសន៍ល្អៗ និងជំរុញលើកទឹកចិត្តដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានចូលរួមនៅក្នុងការអនុវត្តគម្រោងរហូតទទួលបានជោគជ័យ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណជូនចំពោះ **លោកជំទាវ ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ដែលបានយកចិត្តទុកដាក់ និងបានណែនាំដល់មន្ត្រីចុះស្រង់ទិន្នន័យ និងកែច្នៃទិន្នន័យឲ្យមានគុណភាពល្អ និងឯកឧត្តមប្រធានមន្ទីរផែនការខេត្តទាំង ៣ រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលបានសហការល្អនៅក្នុងអំឡុងពេលចុះស្រង់ទិន្នន័យនៅតាមបណ្ដាខេត្តពាក់ព័ន្ធខាងលើ។

តាងនាមឲ្យអង្គភាពក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សូមស្វាគមន៍ចំពោះការចង់បាននូវព័ត៌មានបន្ថែមអំពីការធ្វើអង្កេតនេះ។

ថ្ងៃអង្គារ ៥រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

*រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០២១*

**អគ្គនាយករងវិទ្យាស្ថានជាតិស្ថិតិ និង ជា**

**ប្រធានអង្គភាពក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា**

**បណ្ឌិត ម៉េង គីមហ៊ី**

# មាតិកា

ទំព័រ

និមិត្តសញ្ញាសំគាល់ក្រុមសង្កេតការណ៍ភពផែនដីកម្ពុជា ........ i
បុព្វកថា ........ ii
អារម្ភកថា ........ iv

**ជំពូក ១ សេចក្តីផ្តើម** ........ ១
១.១ សេចក្តីផ្តើម ........ ១
១.២ គោលបំណង ........ ២
១.៣ វិធីសាស្ត្រប្រមូលទិន្នន័យ ........ ២
១.៤ ការកែច្នៃទិន្នន័យ ........ ៣
១.៥ សារៈប្រយោជន៍ ........ ៣

**ជំពូក ២ ស្ថានភាពទូទៅ** ........ ៤
២.១ ប្រជាសាស្ត្រ ........ ៤
២.១.១ និន្នាការចំនួនប្រជាជន ........ ៤
២.១.២ ដង់ស៊ីតេប្រជាជន ........ ៦
២.១.៣ ការបំលាស់ទីកន្លែងរស់នៅ ........ ៨
២.១.៤ ការងារ និងសេដ្ឋកិច្ច ........ ១១
២.២. ទីប្រជុំ គ្រួសារ អាគារ និងលំនៅដ្ឋាន ........ ១៣
២.២.១ ទីប្រជុំជន ........ ១៣
២.២.២ គ្រួសារ និងអាគារ ........ ១៥
២.២.៣ លំនៅដ្ឋាន ........ ១៦
២.៣ បរិស្ថាន ទឹកស្អាត និងបង្គន់អនាម័យ ........ ១៨
២.៣.១ បរិស្ថាន ........ ១៨
២.៣.២ ទឹកស្អាត និងទឹកកខ្វក់ ........ ២១
២.៣.៣ បង្គន់អនាម័យ ........ ២៤
២.៤ គ្រោះមហន្តរាយ ........ ២៦
២.៥ ការប្រែប្រួលអាកាសធាតុ ........ ៣០
២.៥.១ ស្ថានភាពទឹកភ្លៀង ........ ៣០
២.៥.២ សីតុណ្ហភាព ........ ៣២
២.៥.៣ កម្ពស់ទឹក ........ ៣៤

**ជំពូក ៣ ការវិភាគលទ្ធផល** ........ ៣៦
៣.១ ព័ត៌មានទូទៅ ........ ៣៦
៣.១.១ គ្រួសារ ........ ៣៦

៣.១.២ ទំហំគ្រួសារ.......................................................................................៣៧
៣.១.៣ ចំណាកស្រុក ....................................................................................៣៨
៣.១.៤ ការចូលរួមកម្លាំងពលកម្ម................................................................... ៤២
៣.២ បរិស្ថាន .............................................................................................៤៤
៣.២.១ បង្គន់អនាម័យ.....................................................................................៤៤
៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និង ផលប៉ះពាល់ពីការចាក់សំរាម......៤៦
៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬ រោងចក្រការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត............................................. ៤៧
៣.៣ គ្រោះមហន្តរាយ ................................................................................ ៤៧
៣.៤ ការប្រែប្រួលអាកាសធាតុ ..................................................................៥០
៣.៤.១ ស្ថានភាពទឹកភ្លៀង..................................................................................៥០
៣.៤.២ ស្ថានភាពសីតុណ្ហភាព............................................................................៥១
**ជំពូក ៤ បញ្ហាប្រឈម របកគំហើញ ដំណោះស្រាយ និង សន្និដ្ឋាន** .................. ៥២
៤.១ បញ្ហាប្រឈម .................................................................................... ៥២
៤.១.១ សម្ភារៈ និង ឧបករណ៍បច្ចេកទេស ....................................................... ៥២
៤.១.២ ទីប្រឹក្សាបច្ចេកទេស និង ថវិកា.............................................................. ៥២
៤.១.៣ សមត្ថភាពមន្ត្រី .................................................................................. ៥៣
៤.២ របកគំហើញ ..................................................................................... ៥៣
៤.២.១ កំណើនប្រជាជន និងការធ្វើចំណាកស្រុក.................................................. ៥៣
៤.២.២ តំបន់ទីប្រជុំជនមានការកើនឡើង ......................................................... ៥៣
៤.២.៣ បរិស្ថាន...............................................................................................៥៤
៤.២.៤ គ្រោះមហន្តរាយ......................................................................................៥៤
៤.២.៥ ការប្រែប្រួលអាកាសធាតុ .......................................................................៥៤
៤.៣ ដំណោះស្រាយ ...................................................................................៥៥
៤.៤ សន្និដ្ឋាន .............................................................................................៥៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សេចក្តីផ្តើម

ប្រទេសកម្ពុជា គឺត្រូវបាននាយកលេខាធិការនៃលេខាធិការដ្ឋាន ក្រុមសង្កេតការណ៍ភពផែនដីប្រកាសជាផ្លូវការចូលជាសមាជិកទី ១០៤ នៃក្រុមសង្កេតការណ៍ភពផែនដីនៅក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាលើកទី១៤ ដែលបានប្រារព្ធធ្វើពីថ្ងៃទី ២៥ ដល់ ២៦ ខែ តុលា ឆ្នាំ២០១៧ នៅទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក ដែលមានវត្តមាន **ឯកឧត្តម ជុំ ប៊ុនរ៉ុង** ឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនសហរដ្ឋអាមេរិក តំណាងឲ្យប្រទេសកម្ពុជា ព្រមទាំងមានការចូលរួមពីលេខាទី១របស់ស្ថានទូត និងមន្ត្រីជាន់ខ្ពស់របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការតាមរយៈសំណើរបស់ **ឯកឧត្តមអភិក្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៧ ទៅនាយកលេខាធិការនៃលេខាធិការដ្ឋាន ក្រុមសង្កេតការណ៍ភពផែនដី (GEO) ដែលមានទីស្នាក់ការនៅទីក្រុងហ្សឺណែវប្រទេសស្វីស។ បន្ទាប់ពីបានចូលជាសមាជិកក្រុមសង្កេតការណ៍ភពផែនដីជាផ្លូវការរួចមក អង្គភាពក្រុមសង្កេតការណ៍ភពផែនដីស្ថិតក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការត្រូវបានបង្កើតឡើង ដើម្បីងាយស្រួលធ្វើកិច្ចការងារផ្សេងៗជាមួយអគ្គលេខាធិការដ្ឋានក្រុមសង្កេតភពផែនដី ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវប្រទេសស្វីស ។ ការងារសំខាន់របស់ប្រទេសជាសមាជិកក្រុមសង្កេតការភពផែនដី គឺសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យ ដែលបានមកពីផ្កាយរណប ឬ ឧបករណ៍ផ្សេងៗ ដែលថតរូបភាពពីលើអាកាស សម្រាប់ធ្វើការតាមដានត្រួតពិនិត្យបរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ។ ដោយឡែក ចំពោះប្រទេសកម្ពុជា ពេលបច្ចុប្បន្ននេះ ពុំមានផ្កាយរណប ឬ ឧបករណ៍ថតពីលើអាកាសទេ ឬ ទទួលបានការចែករំលែកទិន្នន័យពីផ្កាយរណបពីបណ្តាប្រទេសផ្សេងទៀតដែលមានផ្កាយរណប។ ហេតុដូច្នេះ ជំនួសការប្រមូលទិន្នន័យត្រូវធ្វើតាមរយៈការសម្ភាសន៍មេភូមិ និង មេគ្រួសារដែលរស់នៅក្នុងតំបន់គោលដៅនោះវិញ។ សម្រាប់ការអនុវត្តការងារជំហានទី១ នៅឆ្នាំ២០១៩ អង្គភាពក្រុមសង្កេតការណ៍ភពផែនដី បានអនុវត្តគម្រោងសកម្មភាពការងារ ដែលបានផ្តោតទៅលើខេត្ត៥ នៅជាប់បឹងទន្លេសាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ ដោយប្រើប្រាស់ថវិការាជរដ្ឋាភិបាលកម្ពុជាតាមរយៈថវិកាកម្មវិធីរបស់ក្រសួងផែនការដែលមានចំនួនកំណត់។ នៅក្នុងឆ្នាំ ២០២០ នេះ សកម្មភាពចុះស្រង់ទិន្នន័យអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា នៅក្នុងតំបន់ខ្ពង់រាបនៅក្នុងខេត្ត ៣ រួមមាន ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលគម្រោងអនុវត្ត ៥ ខេត្តដូចឆ្នាំ ២០១៩ ដែរ តែដោយសារបញ្ហាជំងឺឆ្លងកូវីដ ១៩ ត្រូវបានរាជរដ្ឋាភិបាលឲ្យកាត់សកម្មភាព ៥០ភាគរយ។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃការអនុវត្តគម្រោងនេះ គឺការកសាងប្រព័ន្ធទិន្នន័យស្ថិតិទាក់ទងបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុសម្រាប់តំបន់ខ្ពង់រាបនៅក្នុងខេត្ត ៣ គឺខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដើម្បីចូលរួមតាមដានលើការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## ១.៣ វិធីសាស្រ្តប្រមូលទិន្នន័យ

ទិន្នន័យសម្រាប់ធ្វើការវិភាគនេះ គឺបានមកពីការប្រមូលទិន្នន័យពីរប្រភេទ គឺទិន្នន័យទី១ និង ទិន្នន័យទី២។ វិធីសាស្រ្តនៃការប្រមូលទិន្នន័យទី១ គឺត្រូវបានប្រមូលតាមរយៈការធ្វើសម្ភាសន៍មេភូមិ និងមេគ្រួសារនៅក្នុងភូមិគោលដៅនៃខេត្តទាំង ៣ ស្ថិតនៅតំបន់ខ្ពង់រាប។ កម្រងសំណួរសម្រាប់សម្ភាសន៍មានពីរ គឺកម្រងសំណួរសម្រាប់សម្ភាសន៍មេភូមិ និងកម្រងសំណួរសម្រាប់សម្ភាសន៍មេគ្រួសារ ។ ចំនួនភូមិគោលដៅ ៩ភូមិ និង ចំនួនមេគ្រួសារ ៩០០ នាក់ ស្ថិតនៅក្នុងខេត្ត៣ ស្ថិតក្នុងតំបន់ខ្ពង់រាប គឺត្រូវបានធ្វើសម្ភាសន៍។ ទិន្នន័យទី ២ គឺត្រូវបានប្រមូលពីក្រសួងបរិស្ថាន ក្រសួងធនធានទឹក និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងស្ថាប័នពាក់ព័ន្ធដទៃទៀត ដែលបានផលិតចេញជារបាយការណ៍ផ្សេងៗ។

តារាង ១.១ បង្ហាញពីបញ្ជីភូមិគោលដៅសម្រាប់ធ្វើការសម្ភាសន៍ស្រង់ទិន្នន័យ នៅក្នុងខេត្ត ៣ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាប រួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង។

**តារាង ១.១ បញ្ជីភូមិសម្រាប់សម្ភាសន៍**

| ល.រ | ខេត្ត | ស្រុក | ឃុំ | ភូមិ | ចំនួនគ្រសារ | ចំនួនគ្រួសារត្រូវសម្ភាសន៍ |
|---|---|---|---|---|---|---|
| ១ | កំពង់ឆ្នាំង | ស្រុកទឹកផុស | ខ្នងពពក | ក្រោយវត្ត | 239 | 100 |
| | | | ជៀប | ឆកកណ្ដាល | 354 | 100 |
| | | | ទួលខ្ពស់ | ឡ | 173 | 100 |
| ២ | ពោធិ៍សាត់ | កណ្ដៀង | ស្រែស្ដុក | ព្រីងខ្ពស់ | 230 | 100 |
| | | | ស្រែស្ដុក | ក្ដីឈ្វិត | 225 | 100 |
| | | | ស្រែស្ដុក | គ្រង់ | 236 | 100 |
| ៣ | បាត់ដំបង | បាណន់ | ភ្នំសំពៅ | កំប៉ូវ | 398 | 100 |
| | | សង្កែ | នរា | នរា១ | 457 | 100 |
| | | ថ្មគោល | ជ្រៃ | ហៃសាន | 769 | 100 |
| សរុប | | | | | 3,081 | 900 |

## ១.៤ ការកែច្នៃទិន្នន័យ

ទិន្នន័យដែលបានមកពីការធ្វើសម្ភាសន៍តាមរយៈមេភូមិ និង មេគ្រួសារនៅតាមភូមិគោលដៅនៅក្នុងខេត្តទាំង ៣ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាប គឺត្រូវបានវាយបញ្ចូលទៅក្នុងកុំព្យូទ័រ ដោយប្រើប្រាស់កម្មវិធី CSPro 7.4 និងការពិនិត្យកំហុស និងការផលិតជាតារាងសម្រាប់ធ្វើការវិភាគក៏បានប្រើប្រាស់កម្មវិធី CSPro 7.4 នេះផងដែរ ។ ចំពោះកម្មវិធី Microsoft Excel គឺត្រូវបានប្រើប្រាស់សម្រាប់ការធ្វើក្រាហ្វិក និង កម្មវិធី Microsoft Word គឺសម្រាប់សរសេររបាយការណ៍វិភាគទិន្នន័យ។

## ១.៥ សារៈប្រយោជន៍

របាយការណ៍វិភាគទិន្នន័យនេះ គឺមានសារៈសំខាន់ដល់អ្នកសិក្សាស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នករៀបចំគោលនយោបាយផ្សេងៗ ជាពិសេសរាជរដ្ឋាភិបាលមានទិន្នន័យបន្ថែមទៀតសម្រាប់រៀបចំគោលនយោបាយទាក់ទងទៅនឹងការត្រួតពិនិត្យតាមដានលើផ្នែកបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុតាមតំបន់នីមួយៗនៅក្នុងប្រទេសកម្ពុជា និងមានវិធានការបង្ការនូវហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងដោយសារគ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុជាដើម។

# ជំពូក ២
# ស្ថានភាពទូទៅ

## ២.១ ប្រជាសាស្ត្រ
### ២.១.១ និន្នាការចំនួនប្រជាជន

ចំនួនប្រជាជនសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្ហាញតាមរយៈការធ្វើជំរឿនប្រជាជន ឆ្នាំ ១៩៦២ មានចំនួន៥,៧ លាននាក់ បានកើនឡើងដល់ចំនួន ១១,៤ លាននាក់ ផ្អែកតាមការធ្វើជំរឿនប្រជាជនឆ្នាំ ១៩៩៨ រយៈពេល៣៦ឆ្នាំនេះប្រជាជនកម្ពុជា បានកើនឡើងជាង២ដងស្មើនឹងចំនួន៧,៧ លាននាក់ ។ ចំនួនប្រជាជនក្នុងរយៈពេល១០ឆ្នាំ គិតចាប់ពីឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៨ មានការកើនឡើងប្រហែលចំនួន ២លាននាក់ (៩,៥%) ហើយក្នុងរយៈពេល ១១ឆ្នាំ គិតចាប់ពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៩ កើនឡើងចំនួន ១,៩លាននាក់ (១៤,១%) នឹងត្រូវបានគេរំពឹងទុកថានៅឆ្នាំ ២០៣០ ចំនួនប្រជាជនកម្ពុជាអាចកើនដល់ ១៨,៤លាននាក់។ ក្រាហ្វិក២.១ បង្ហាញអំពីនិន្នាការចំនួនប្រជាជនសរុប ទូទាំងប្រទេសផ្អែកតាមទិន្នន័យអង្កេត និង ជំរឿនប្រជាជនតាមបណ្ដាឆ្នាំ។

**ក្រាហ្វិក ២.១ និន្នាការចំនួនប្រជាជនសរុបទូទាំងប្រទេស**




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

ចំនួនប្រជាជននៃខេត្តទាំងបីមានការកើនឡើងពី ១,៦ លាននាក់ នៅឆ្នាំ ១៩៩៨ កើនឡើងដល់ ២,៧ លាននាក់នៅឆ្នាំ ២០៣០ ។ ខេត្តបាត់ដំបងមានចំនួនប្រជាជនកើនពី ០,៨ លាននាក់ កើនដល់ ១,៥ លាននាក់ ពីឆ្នាំ ១៩៩៨ ដល់ ឆ្នាំ ២០៣០ ខណៈដែល ខេត្តកំពង់ឆ្នាំងមានចំនួនប្រជាជនកើនពី ០,៤២ លាននាក់ កើនដល់ ០,៦៣ លាននាក់ និង ខេត្តពោធិ៍សាត់កើនពី ០,៣៦ លាននាក់កើនដល់ ០,៥៥ លាននាក់ ពីឆ្នាំ ១៩៩៨ ដល់ ២០៣០។

**ក្រាហ្វិក ២.២ និន្នាការចំនួនប្រជាជនសម្រាប់ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង**




*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៦២, ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

បើប្រៀបធៀបចំនួនប្រជាជនខេត្តទាំង ៣ ខាងលើជាមួយនឹងចំនួនប្រជាជនទូទាំងប្រទេសមានចំនួន ១៣,៧ ភាគរយ នៅឆ្នាំ ១៩៩៨ ហើយបានកើនឡើងដល់ ១៤,៧ ភាគរយ នៅឆ្នាំ ២០៣០ ខណៈដែលចំនួនប្រជាជនខេត្តទាំង ៣ ធៀបនឹងខេត្តទាំង ៨ ជាប់បឹងទន្លេសាបមានចំនួន ៤៥,៤ ភាគរយ នៅឆ្នាំ ១៩៩៨ និង ៤៣,៩ ភាគរយ នៅឆ្នាំ ២០៣០។

### តារាង ២.១ ចំនួនប្រជាជនសរុប ពីឆ្នាំ ១៩៩៨ ដល់ ២០៣០ គិតជាពាន់នាក់

| ឆ្នាំ | កំពង់ឆ្នាំង | ពោធិ៍សាត់ | បាត់ដំបង | សរុប ៣ ខេត្ត | តំបន់បឹងទន្លេសាប | កម្ពុជា |
|---|---|---|---|---|---|---|
| 1998 | 418 | 360 | 793 | 1,571 | 3,460 | 11,438 |
| 2004 | 532 | 456 | 972 | 1,960 | 4,172 | 12,824 |
| 2008 | 472 | 397 | 1,025 | 1,894 | 4,357 | 13,396 |
| 2013 | 523 | 436 | 1,121 | 2,080 | 4,720 | 14,677 |
| 2017 | 551 | 491 | 1,268 | 2,310 | 5,266 | 15,685 |
| 2019 | 872 | 412 | 987 | 2,271 | 5,148 | 15,288 |
| 2025 | 607 | 515 | 1,431 | 2,553 | 5,400 | 17,519 |
| 2030 | 629 | 553 | 1,519 | 2,701 | 6,153 | 18,391 |

*ប្រភព៖ ១. ទិន្នន័យឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ផ្អែកលើទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩*
*២. ទិន្នន័យឆ្នាំ ២០០៤ និង ២០១៣ ផ្អែកលើអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣*
*៣. ទិន្នន័យឆ្នាំ ២០១៧ ផ្អែកលើទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តទាំង ៥*
*៤. ទិន្នន័យឆ្នាំ ២០២៥ និង ២០៣០ ផ្អែកលើទិន្នន័យចំណោលប្រជាជនឆ្នាំ ២០១១*

## ២.១.២ ដង់ស៊ីតេប្រជាជន

ដង់ស៊ីតេប្រជាជនជាសូចនាករមួយយ៉ាងសំខាន់សម្រាប់ពិនិត្យមើលរបាយប្រជាជនតាមតំបន់ រាជធានី ខេត្ត ។ ដង់ស៊ីតេចំនួនប្រជាជនទូទាំងប្រទេសនៅឆ្នាំ ១៩៩៨ មានដង់ស៊ីតេចំនួន ៦៤នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើង ៧៥ ក្នុងមួយគីឡូម៉ែត្រការ៉េ និង កើនឡើងដល់ ៨៦នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ២០១៩ ខណៈដែលខេត្តទាំង ៣ មានដង់ស៊ីតេចំនួន ៥៣ នាក់ក្នុងមួយ គីឡូម៉ែត្រការ៉េ នៅឆ្នាំ ១៩៩៨ នឹងកើនឡើងដល់ ៦៤ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅឆ្នាំ ២០១៩។ ចំណែក ឯនៅក្នុងតំបន់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៥៧ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ ២០០៨ និង បានកើនឡើង ៦២នាក់ក្នុងមួយគីឡូម៉ែត្រការ៉េក្នុងឆ្នាំ ២០១៩។ ចំណែកឯខេត្តទាំង ៥ ជាប់បឹងទន្លេសាបមានដង់ស៊ីតេចំនួន ៦៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ ហើយបានកើនឡើងដល់ ៧៣ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េនៅក្នុងឆ្នាំ ២០១៩ ខណៈខេត្តទាំង ៣ មារួមមាន ខេត្តកំពង់ឆ្នាំង ពោធិសាត៏ និងខេត្តបាត់ដំបងមានចំនួន ៧០ នាក់ក្នុងមួយគីឡូម៉ែត្រការ៉េ។

# រូបភាព ២.៣ ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ១៩៩៨




ប្រភព: លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ ១៩៩៨

# រូបភាព ២.៤ ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ២០០៨




ប្រភព: លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ ២០០៨

### រូបភាព ២.៥ ដង់ស៊ីតេប្រជាជនតាមរាជធានីខេត្ត ឆ្នាំ ២០១៩




ប្រភព: លទ្ធផលចុងក្រោយជំរឿនទូទៅនូវប្រជារាស្ត្រ ឆ្នាំ ២០១៩

## ២.១.៣ ការបំលាស់ទីកន្លែងរស់នៅ

ការផ្លាស់ប្តូរទីកន្លែងរស់នៅ ឬ ការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជនកម្ពុជា គឺត្រូវបានកំណត់ជាដំណើរការនៃការផ្លាស់ប្តូរកន្លែងរស់នៅ ពីទីតាំងភូមិសាស្ត្រមួយទៅទីតាំងភូមិសាស្ត្រមួយទៀត។ យោងតាមអនុសាសន៍របស់អង្គការសហប្រជាជាតិ បានឲ្យគ្រប់ប្រទេសទាំងអស់លើពិភពលោកបញ្ចូលសូចនាករនេះទៅក្នុងតារាងបញ្ជីសំណួរនៃការធ្វើជំរឿនប្រជាជន ដើម្បីសិក្សាអំពីចរិកលក្ខណៈនៃការផ្លាសប្តូរលំនៅដ្ឋាន។ ជាក់ស្តែងផងដែរ រាជរដ្ឋាភិបាលកម្ពុជាមានទិន្នន័យសម្រាប់ការរៀបចំគោលនយោបាយជាតិទាក់ទងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងរកវិធីសាស្ត្រណាទប់ស្កាត់ការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជន តាមរយៈការអភិវឌ្ឍ និងបង្កើតការងារនៅក្នុងស្រុក ឬ នៅទីតាំងជិតលំនៅដ្ឋានរបស់ពួកគាត់តែម្តង ។ នៅឆ្នាំ ១៩៩៨ ប្រជាជនទូទាំងប្រទេសមានការផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣១ភាគរយ ហើយបានកើនឡើង ៣៥ភាគរយនៅឆ្នាំ ២០០៤ ប៉ុន្តែនៅឆ្នាំ ២០០៨ បានធ្លាក់ចុះមកត្រឹម ២៦,៥ភាគរយ និងបានកើនឡើងវិញនៅឆ្នាំ ២០១៣ មានចំនួន ២៨,៩ភាគរយ និងបានធ្លាក់ចុះមកត្រឹម ២១,៥ភាគរយ នៅឆ្នាំ ២០១៩។

## រូបភាព ២.៦ ការផ្លាស់ប្តូរទីលំនៅពីមុនទូទាំងប្រទេស




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជាពស្ត្រកម្ពុជា អង្កេតចន្លោះជំរឿន ឆ្នាំ ២០០៤
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជាពស្ត្រកម្ពុជាឆ្នាំ ២០១៣
- លទ្ធផលបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅដ្ឋានរបស់ប្រជាជនកម្ពុជា នៅតាមតំបន់ទីប្រជុំជន គឺមានចំនួនច្រើនជាងតំបន់ជនបទទាំងនៅឆ្នាំ ២០០៨ និង ២០១៣ ។ នៅឆ្នាំ ២០០៨ ប្រជាជនដែលបានផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៥៩,៧ភាគរយ ហើយបានថយចុះនៅឆ្នាំ ២០១៣ ដែលមានចំនួន ៤៩,៤ភាគរយ ខណៈដែលតំបន់ជនបទនៅឆ្នាំ ២០០៨ មានចំនួន ១៨,៩ ភាគរយ ហើយបានកើនឡើងដល់ ២៣,៣ ភាគរយ នៅឆ្នាំ ២០១៣ និងបានធ្លាក់ចុះមកត្រឹម ១២,៤ភាគរយ នៅឆ្នាំ ២០១៩។

### រូបភាព ២.៧ ការផ្លាស់ប្តូរទីលំនៅតាមតំបន់




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជាពស្ត្រកម្ពុជាឆ្នាំ ២០១៣
- លទ្ធផលបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

នៅក្នុងឆ្នាំ ២០០៨ និង ២០១៣ មូលហេតុចម្បងនៃការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជនមានចំនួនច្រើនជាងគេក្នុងចំណោមមូលហេតុដទៃទៀតនៃការផ្លាស់ប្តូរលំនៅដ្ឋាន។ នៅឆ្នាំ ២០០៨ មូលហេតុគ្រួសារផ្លាស់ប្តូរលំនៅដ្ឋានមានចំនួន ៣៧,៥ ភាគរយ និងបានកើនឡើងដល់ ៤២,២ភាគរយ នៅឆ្នាំ ២០១៣ និងធ្លាក់ចុះមកត្រឹម ៣៨,៩ភាគរយ ។ មូលហេតុរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ២០១៩ មានចំនួនច្រើនជាង ឆ្នាំ ២០០៨ ចំនួន ៥,១ ភាគរយ ហើយមូលហេតុ កូនកំព្រាក៏មានចំនួនថយចុះពី ៥,៦ ភាគរយ នៅឆ្នាំ ២០០៨ មកត្រឹម ០,២ ភាគរយ នៅឆ្នាំ ២០១៩។ មូលហេតុនៃការស្វែងរកការងារធ្វើបានធ្លាក់ចុះបន្តិចពី ២១,៥ភាគរយ នៅឆ្នាំ ២០០៨ ធ្លាក់មកត្រឹម ១៩,៦ ភាគរយ ខណៈដែលមូលហេតុនៃការសិក្សាមានលក្ខណៈប្រហាក់ប្រហែលគ្នា។

រូបភាព ២.៨ មូលហេតុនៃការផ្លាស់ប្តូរទីលំនៅ




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨

- របាយការណ៍ចុងក្រោយ អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ ២០១៣
- លទ្ធផលបណ្តោះអាសន្ននៃជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## ២.១.៤ ការងារ និងសេដ្ឋកិច្ច

ប្រជាជនកម្ពុជាអ្នកមានការងារធ្វើសម្រាប់ទូទាំងប្រទេសមានចំនួនលើសពី ៩០ ភាគរយ ចាប់តាំងពីឆ្នាំ ១៩៩៨ ដល់ ២០១៩ ។ នៅក្នុងឆ្នាំ ១៩៩៨ អ្នកមានការងារធ្វើមានចំនួន ៩៤,៧ ភាគរយ នៅឆ្នាំ២០០៨ បានកើនឡើងដល់ ៩៨,៣ ភាគរយ និងនៅឆ្នាំ ២០១៩ បានកើនឡើងដល់ ៩៩,១ ភាគរយ ។ អត្រាអ្នកគ្មានការងារធ្វើនៅឆ្នាំ ១៩៩៨ មានចំនួន ៥,៣៤ ភាគរយ ច្រើនជាងឆ្នាំ ២០០៨ ដែលមានចំនួន ១,៧ ភាគរយ និងឆ្នាំ ២០១៩ មានចំនួន ០,៩ ភាគរយ ។ រូបភាព ២.៩ ខាងក្រោម បង្ហាញអំពីអត្រាអ្នកគ្មានការងារធ្វើពីឆ្នាំ ១៩៩៨ ដល់ ២០១៩។

### រូបភាព ២.៩ អត្រាអ្នកគ្មានការងារធ្វើ




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

អត្រាអ្នកមានការងារធ្វើ ត្រូវបានបែងចែកតាមវិស័យសេដ្ឋកិច្ចចម្បងៗរួមមាន វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។ នៅក្នុងឆ្នាំ១៩៩៨ អត្រាចូលរួមកម្លាំងពលកម្មក្នុងវិស័យកសិកម្មមានចំនួន ៧៧,៥ ភាគរយ ហើយបានថយចុះមកត្រឹម ៧២,៣ ភាគរយ នៅឆ្នាំ ២០០៨ និងបន្តធ្លាក់ចុះមានចំនួន៥៤,០ភាគរយ នៅឆ្នាំ២០១៩ ខណៈដែលអត្រានៃការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មមានការកើនឡើង។ នៅក្នុងឆ្នាំ ២០០៨ អត្រានៃការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្មមានចំនួន ៨,៥ ភាគរយ និង វិស័យសេវាកម្មមានចំនួន ១៩,២ ភាគរយ និងនៅឆ្នាំ ២០១៩ អត្រាចូលរួមកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មមានចំនួន ១៨,៦ ភាគរយ និង វិស័យសេវាកម្មមានចំនួន ២៧,៤ ភាគរយ ។

រូបភាព ២.១០ ការបែងចែកភាគរយអ្នកមានការងារធ្វើតាមវិស័យសេដ្ឋកិច្ច




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រឆ្នាំ ២០១៩

## ២.២ ទីប្រជុំជន គ្រួសារ អគារ និងលំនៅដ្ឋាន

### ២.២.១ ទីប្រជុំជន

ការកើនឡើងនូវនគរូបនីយកម្ម នៅលើពិភពលោកបានធ្វើឲ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងសម្រាប់ពិភពលោកនិងតាមប្រទេសនីមួយៗ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកែសម្រួលតំបន់រដ្ឋបាលញឹកញាប់ចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន។ ការកែសម្រួលតំបន់រដ្ឋបាលនេះ ក៏ជាកត្តាមួយដែលធ្វើឲ្យមានការកើនឡើងនូវតំបន់ទីប្រជុំជន ដោយសារតំបន់មួយចំនួនក្លាយជាក្រុងជាគោលដៅអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រប់ផ្នែក និងលំនៅដ្ឋានទៀតផង។ ដូច្នេះផ្ទៃដីស្រែមួយចំនួនត្រូវបានបង្វែរមុខងារពីដីកសិកម្ម ទៅជាដីសម្រាប់ការសាងសង់នៅពេលអនាគត ។ កន្លងមកការកំណត់តំបន់ទីប្រជុំជនពុំមាននិយមន័យច្បាស់លាស់នៅឡើយទេ ។ នៅឆ្នាំ ១៩៩៨ ទីប្រឹក្សាជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨ បានកំណត់ស្រុកដែលស្ថិតក្នុងទីរួមខេត្តជាទីប្រជុំជន ។ នៅឆ្នាំ ២០០៤ ជំនាញការរបស់

មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជននៅឆ្នាំ ២០០៤ បានកំណត់និយមន័យទីប្រជុំជន ដោយកំណត់ ៣ លក្ខខណ្ឌគឺ៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅឆ្នាំ ២០១១ និយមន័យលក្ខខណ្ឌទីប្រជុំជនបានកែសម្រួលនៅលក្ខខណ្ឌទី ៣ គឺ ភាគរយបុរសធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ទៅជាភាគរយប្រជាជនទាំងពីរភេទធ្វើការនៅក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ ហើយលក្ខខណ្ឌទី ១ និងទី ២ គឺរក្សានៅដដែល។ លក្ខខណ្ឌទាំងនោះគឺ៖

១) ចំនួនប្រជាជនទាបបំផុតចាប់ពី ២.០០០ នាក់ឡើង ក្នុងមួយឃុំ

២) ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រការ៉េចាប់ពី ២០០នាក់ ឡើង

៣) ភាគរយចំនួនប្រជាជនទាំងពីរភេទធ្វើការក្នុងវិស័យកសិកម្មទាបជាង ៥០ភាគរយ

នៅក្នុងរូបភាព ២.៩ បង្ហាញអំពីភាគរយចំនួនប្រជជានរស់នៅតំបន់ទីប្រជុំជន ដែលមាននិន្នាការកើនឡើងជាលំដាប់។ នៅក្នុងឆ្នាំ ១៩៩៨ ចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំផ្អែកលើការកំណត់ស្រុកក្នុងទីរួមខេត្តជាតំបន់ទីប្រជុំជនមានចំនួន ១៥,៧ភាគរយ ហើយនៅឆ្នាំ២០០៤ ការកំណត់និយមន័យទីប្រជុំថ្មីដោយប្រើប្រាស់ទិន្នន័យជំរឿនឆ្នាំ ១៩៩៨ ដដែលគឺមានការកើនចំនួន ២ ភាគរយ។ លទ្ធផលនៃការធ្វើជំរឿននៅឆ្នាំ ២០០៨ បានអនុវត្តន៍និយមន័យទីប្រជុំជនឆ្នាំ ២០០៤ គឺចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជនមានចំនួន ១៩,៥ ភាគរយ និងផ្អែកលើនិយមន័យទីប្រជុំជនថ្មីឆ្នាំ ២០១១ ចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជនមានការកើនឡើងដល់ ២៧,១ ភាគរយ ។ ភាគរយចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជននៅឆ្នាំ ២០១៨ តាមការប៉ាន់ស្មានមានចំនួន ៣៣,៦ ភាគរយ នឹងនៅឆ្នាំ ២០៣០ អាចកើនឡើងរហូតដល់ ៤៣ ភាគរយ ។ ទោះបីជានិយមន័យមានការខុសគ្នាយ៉ាងណាក៏ដោយ ជាក់ស្តែងប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនមានការកើនឡើង ដោយសារកត្តាការកើនឡើងលំនៅដ្ឋានថ្មីៗ ការស្វែងរកការងារដែលពួកគាត់គិតថាមានលក្ខណៈប្រសើរជាងកន្លែងរស់នៅចាស់ និងកត្តាសេដ្ឋកិច្ចផ្សេងៗ។

### រូបភាព ២.១១ ភាគរយចំនួនប្រជាជនរស់នៅតំបន់ទីប្រជុំជន




ប្រភព៖ ការកំណត់ចំណាត់ថ្នាក់ទីប្រជុំជនឡើងវិញ ឆ្នាំ ២០១១

## ២.២.២ គ្រួសារ និងអាគារ

សូចនាករចំនួនគ្រួសារ គឺជាសូចនាករមួយមានសារៈសំខាន់ណាស់ទាក់ទងទៅនឹងការផ្តល់សេវាផ្សេងៗដូចជាអគ្គិសនី ទឹកស្អាត បង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត។ ចំនួនគ្រួសារសរុបនៅឆ្នាំ ១៩៩៨ មានចំនួន ២,១៦ លានគ្រួសារ ហើយបានកើនឡើងរហូតដល់ ៣,៣៤ លានគ្រួសារ នៅឆ្នាំ ២០១៩ សម្រាប់ទូទាំងប្រទេស។ ចំនួនអគារនៅទូទាំងប្រទេស ប្រហែលជិត ២ លានអគារ នៅឆ្នាំ ១៩៩៨ និងបានកើនឡើងដល់ ៣ លានអគារ នៅឆ្នាំ ២០១៩ ខណៈដែលខេត្តទាំង ៣ នៅឆ្នាំ ១៩៩៨ មានចំនួនគ្រួសារ ២៩៤.៨៨៤ ដែលមានចំនួនអាគារប្រមាណ ២៦៥.៣៩៦ និងនៅឆ្នាំ ២០១៩ មានអគារប្រហែល ៤៣៣, ៤២៣ អគារ បើគិតជាចំនួនអគារគិតជាមធ្យមមានប្រមាណ ៩០ភាគរយ នៃចំនួនគ្រួសារ។

តារាង ២.២ ចំនួនគ្រួសារ និង អាគារ

| ឆ្នាំ | ចំនួនគ្រួសារ | | | ចំនួនអគារ | | |
|---|---|---|---|---|---|---|
| | ខេត្តទាំង ៣ | តំបន់បឹងទន្លេសាប | កម្ពុជា | ខេត្តទាំង ៣ | តំបន់បឹងទន្លេសាប | កម្ពុជា |
| 1998 | 294,884 | 661,962 | 2,162,086 | 265,396 | 598,447 | 1,954,634 |
| 2008 | 393,915 | 905,039 | 2,817,637 | 377,107 | 818,201 | 2,637,654 |
| 2019 | 457,398 | 1,067,469 | 3,341,770 | 433,423 | 965,045 | 3,021,127 |

រូបភាព ២.១២ ចំនួនគ្រួសារ និងអគារ




## ២.២.៣ លំនៅដ្ឋាន

នៅក្នុងប្រទេសកម្ពុជាមានចំនួនគ្រួសារសរុបប្រហែល ៣,៤ លានគ្រួសារ នៅក្នុងឆ្នាំ ២០១៩ ខណៈដែលនៅក្នុងឆ្នាំ ២០១៧ លំនៅដ្ឋានសរុបនៅក្នុងប្រទេសកម្ពុជា ផ្អែកតាមទិន្នន័យមូលដ្ឋានរបស់មន្ទីរផែនការខេត្តមានចំនួន ៣,៣ លានលំនៅដ្ឋាន។ ចំនួនផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់ មានចំនួន ១,៧ លានផ្ទះ ស្មើនឹង ៥១,៥ភាគ ច្រើនជាងគេ បន្ទាប់មក ផ្ទះដំបូលប្រក់ក្បឿងមានចំនួន ៩៩៤.៨៥៨ ផ្ទះ ស្មើនឹង ៣០ ភាគរយ ស្ថិតក្នុងលំដាប់លេខរៀងទី ២ ខណៈដែលផ្ទះថ្មមិនមែនបេតុងមានចំនួន ១៧៧.៩៧០ ផ្ទះ ស្មើនឹង ៥,៤ ភាគរយ ស្ថិតក្នុងលំដាប់រៀងទី ៣ ។ លំនៅដ្ឋានប្រភេទផ្ទះ

ថ្មល្វែងមានចំនួន ១៦៤,២៩៧ ស្មើនឹង ៥ ភាគរយ ស្ថិតក្នុងលំដាប់រៀងទី ៤ ខណៈដែលផ្ទះដំបូលប្រក់ស្លឹកស្បូវមានចំនួន ១០៥,៦៤១ផ្ទះ ស្មើនឹង ៣,២ ភាគរយ ស្ថិតលំដាប់ទី ៥ និង លំនៅដ្ឋានប្រភេទភូមិគ្រឹះចំនួន ១៣.៧៦២ ស្មើនឹង ០,៤ភាគរយ ស្ថិតលំដាប់ទី ៦ ជាលំដាប់ចុងក្រោយ ។ តែបើទោះបីជាលំនៅដ្ឋានប្រភេទភូមិគ្រឹះមានចំនួនតិចក៏ដោយ បើប្រៀបធៀបជាមួយលំនៅដ្ឋានប្រភេទផ្សេងៗខាងលើក៏ពិតមែន តែចំនួននេះបានបង្ហាញថា ប្រទេសកម្ពុជាមានប្រភេទលំនៅដ្ឋានទំនើបច្រើន ហើយបន្តកើនឡើងទៀត ដែលបញ្ជាក់អំពីកម្រិតជីវភាពរបស់ប្រជាជនកម្ពុជាមានការកើនឡើងផងដែរ។ ចំពោះខេត្តទាំង ៣ មានចំនួនប្រហែលជាង ៥០ ម៉ឺនលំនៅដ្ឋាន ស្មើនឹង ១៥ ភាគរយនៃចំនួនលំនៅដ្ឋានទូទាំងប្រទេស ដែលក្នុងនោះលំនៅដ្ឋានដែលមានដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់មានចំនួនច្រើនជាងគេ និងលំនៅដ្ឋានប្រភេទភូមិគ្រឹះមានចំនួនតិចជាងគេ។

### តារាង ២.៣ ចំនួនលំនៅដ្ឋានតាមប្រភេទ ឆ្នាំ ២០១៧

| ប្រភេទលំនៅដ្ឋាន | ខេត្តទាំង ៣ | តំបន់បឹងទន្លេសាប | កម្ពុជា |
|---|---|---|---|
| ចំនួនផ្ទះដំបូលប្រក់ស្លឹកស្បូវ | 23,431 | 60,100 | 105,641 |
| ចំនួនផ្ទះដំបូលប្រក់ស័ង្កសីហ្វីប្រូស៊ីម៉ង់ | 338,941 | 686,592 | 1,703,217 |
| ចំនួនផ្ទះប្រក់សង្កសីតិចជាង២០សន្លឹក | 31,266 | 61,986 | 146,355 |
| ចំ.ផ្ទះដំបូលប្រក់ក្បឿង | 88,275 | 247,888 | 994,858 |
| ចំ.ផ្ទះថ្មមិនមែនបេតុង | 18,684 | 46,590 | 177,970 |
| ចំ.ផ្ទះថ្មល្វែង | 7,338 | 21,303 | 164,297 |
| ចំ.ផ្ទះភូមិគ្រឹះ(វីឡា) | 894 | 2,115 | 13,762 |
| សរុប | 508,829 | 1,126,574 | 3,306,100 |

ប្រភពៈ ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

រូបភាព ២.១៣ ចំនួនលំនៅដ្ឋាន




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

## ២.៣ បរិស្ថាន ទឹកស្អាត និង បង្គន់អនាម័យ

### ២.៣.១ បរិស្ថាន

ផ្អែកលើទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧ បានបង្ហាញថា ចំនួនគ្រួសារសរុបទូទាំងប្រទេសមានចំនួន ៣.៥០៤.៣៣៣ គ្រួសារ តំបន់បឹងទន្លេសាបមានចំនួន ១,១៧២,៧៨២ គ្រួសារ ស្មើនឹង ៣៦ ភាគរយ ធៀបទៅនឹងចំនួនគ្រួសារសរុបទូទាំងប្រទេស និង ចំនួនគ្រួសារសម្រាប់ខេត្ត ៣ ជាប់បឹងទន្លេសាបមានចំនួន ៥១៨.០៣៦គ្រួសារ ស្មើនឹង ១៥ ភាគរយធៀបទៅនឹងចំនួនគ្រួសារសរុបទូទាំងប្រទេស តិចជាងចំនួនគ្រួសារនៅតំបន់បឹងទន្លេសាប ១១ ភាគរយ។ ចំនួនគ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្សទូទាំងប្រទេសមានចំនួន ៤៩.០៨១ គ្រួសារ (១,៤%) តំបន់បឹងទន្លេសាប ៣៥.០៣៧ គ្រួសារ (៣,០%) និង ខេត្ត ៣ មានចំនួន ២,០៦១ គ្រួសារ(០,៤%)។ ចំនួនគ្រួសារដែលមានសេវាប្រមូលសំរាមតាមផ្ទះនៅទូទាំងប្រទេសមានចំនួន ៣៤៦.៧៥៥ គ្រួសារ (១០%) តំបន់បឹងទន្លេសាប ៥៣.៨៨០ គ្រួសារ (៤,៦%) និង ខេត្ត ៣ មានចំនួន ២១,៣៩០ គ្រួសារ (៤,១%)។ ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាននៅទូទាំងប្រទេសមានចំនួន ៤៣.៤៩៤ គ្រួសារ (១,២%) តំបន់បឹងទន្លេសាប ១៧.៥៣៤ គ្រួសារ (១,៥%) និង ខេត្ត ៣ មានចំនួន ៧,៩៧០ គ្រួសារ (១,៥%) ។

### តារាង ២.៤ ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថានឆ្នាំ ២០១៧

| អធិប្បាយ | ខេត្តទាំង ៣ | តំបន់បឹងទន្លេសាប | កម្ពុជា |
|---|---|---|---|
| គ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្ស | 2,060 | 35,037 | 49,081 |
| គ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 21,390 | 53,880 | 346,755 |
| គ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន | 7,970 | 17,534 | 43,494 |
| **ចំនួនគ្រួសារសរុប** | **518,038** | **1,172,782** | **3,504,333** |

ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

នៅក្នុងរូបភាព ២.១៤ បង្ហាញថា គ្រួសារដែលមានសេវាសំរាមតាមផ្ទះមានតែ ៩,៩ ភាគរយប៉ុណ្ណោះដែលទទួលបានសេវានេះ ហើយចំនួនគ្រួសារចំនួន ៩០,១ ភាគរយទៀតពុំទាន់បានទទួលសេវាប្រមូលសំរាម ។ នៅក្នុងតំបន់បឹងទន្លេសាប ចំនួនគ្រួសារដែលទទួលបានសេវាប្រមូលសំរាមមានតែ ៤,៦ ភាគរយ តិចជាងទូទាំងប្រទេសជាងពាក់កណ្ដាល និង ខេត្ត ៣ ភាគរយចំនួនគ្រួសារដែលបានទទួលសំរាមមានចំនួន ៤,១ ភាគរយ ប្រហាក់ប្រហែលនឹងតំបន់បឹងទន្លេសាបដែរ តែតិចជាងទូទាំងប្រទេសជាងពាក់កណ្ដាលស្មើនឹង ៥,៨ ភាគរយ។

### រូបភាព ២.១៤ ភាគរយគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះឆ្នាំ ២០១៧




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៣ឆ្នាំ ២០១៩ បាន បង្ហាញថា ការផ្តល់សេវាប្រមូលដឹកជញ្ជូនសំរាម សំណល់រឹងនៅទីប្រជុំជន ក្រុង ស្រុក ភាគច្រើនអនុវត្តដោយអ្នកគ្រប់គ្រងផ្សារ ឬ ភាស៊ីផ្សារដែលមានរហូតដល់ ៥៣ ភាគរយ ហើយការផ្តល់សេវានេះដោយក្រុមហ៊ុនឯកជននៅទីប្រជុំជន ក្រុងមានចំនួនតែ ២០ ភាគរយ ប៉ុណ្ណោះ ។ មូលហេតុមកពីនៅតាមទីប្រជុំជនស្រុក ការចូលរួមបង់ថ្លៃសេវាកម្មដឹកជញ្ជូនសំរាម សំណល់រឹងមានតែអាជីករលក់ដូរតាមតូបក្នុងផ្សារ និងហាងទំនិញ ឬ ផ្ទះប្រជាពលរដ្ឋជុំវិញផ្សារតែប៉ុណ្ណោះ ហើយដែលក្រុមហ៊ុនពិបាកនឹងទទួលយក (ទំហំការងារមិនសមាមាត្រនឹងចំណាយរបស់ក្រុមហ៊ុន) ហើយយោងតាមរូបភាព ២.១៥ បង្ហាញថា ២៤ភាគរយ ទៀតពុំទទួលបានសេវាប្រមូលសំរាម សំណល់រឹង ទីប្រជុំជននៅក្នុងក្រុង សំណល់រឹងទូទាំងប្រទេស។

**រូបភាព ២.១៥ ភាគរយការផ្តល់សេវា ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជននៅក្រុង ស្រុក ទាំង១៨៥ទូទាំងប្រទេស ឆ្នាំ ២០១៧**




ប្រភព: ក្រសួងបរិស្ថានឆ្នាំ ២០១៧

នៅក្នុងរូបភាព ២.១៦ បង្ហាញពីបរិមាណសំណល់រឹងទីប្រជុំជន ដែលចាក់នៅទីលានប្រចាំឆ្នាំពី២០០៤ ដល់ឆ្នាំ ២០១៧ (ក្រសួងបរិស្ថាន ២០១៧ច) ។ ជាមួយនឹងកំណើនសន្សឹមៗចាប់ពី ៣១៧.៥៥០ តោន នៅឆ្នាំ ២០០៤ រហូតដល់ប្រមាណជាង ៦៣៥.០០០ តោន ក្នុងឆ្នាំ ២០១១ និងមានសន្ទុះខ្លាំងនៅឆ្នាំ បន្ទាប់គឺប្រមាណជាង ៩៣០.០០០តោន ។ ទិន្នន័យឆ្នាំ ២០១៧ បង្ហាញថាសំណល់រឹងដែលបានចាក់នៅទីលានសរុបមានប្រមាណ ១.៤៥៤.៦៥៣ តោន ធៀបនឹងឆ្នាំ ២០១៦ គឺកើនឡើង ១៨៨.០៣៣តោន ស្មើនឹង ១៤,៨ ភាគរយ និងមានកំណើន ៤៦,៩ភាគរយ ធៀបនឹងឆ្នាំ ២០១៣។

**រូបភាព ២.១៦ បរិមាណសំរាម សំណល់រឹងទីប្រជុំជន ដែលបានចាក់នៅទីលានប្រចាំឆ្នាំ**




ប្រភព: ក្រសួងបរិស្ថានឆ្នាំ ២០១៧

## ២.៣.២ ទឹកស្អាត និងទឹកកខ្វក់

### ក.ទឹកស្អាត

នៅក្នុងប្រទេសកម្ពុជាភាគរយនៃគ្រួសារ ដែលមានទឹកស្អាតនៅឆ្នាំ ១៩៩៨ មានចំនួន ២៩ ភាគរយ ហើយបានកើនឡើងរហូតដល់ ៧៣ ភាគរយនៅឆ្នាំ ២០១៩ ផ្អែកតាមទិន្នន័យជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ ។ នៅក្នុងរវាង១០ឆ្នាំ បើប្រៀបធៀបរវាងឆ្នាំ ១៩៩៨ និង ២០០៨ ភាគរយនៃការប្រើប្រាស់ទឹកស្អាតបានកើនឡើងមានចំនួន ១៨ ភាគរយ និងពីឆ្នាំ ២០០៨ ដល់ ២០១៩ កើនឡើង ២៦ ភាគរយ ។

រូបភាព ២.១៧ ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់នៅទូទាំងប្រទេស




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពរស្ត្របស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពរស្ត្របស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

រូបភាព ២.១៨ បង្ហាញថា ភាគរយគ្រួសារទទួលបានទឹកស្អាត (ទឹកមានលក្ខណៈប្រសើរ) នៅទូទាំងប្រទេសបានកើនឡើងពី ៤៧ភាគរយ នៅឆ្នាំ ២០០៨ ទៅ ៧៣ភាគរយ នៅឆ្នាំ ២០១៩ ។ នៅក្នុងឆ្នាំ ២០១៩ ខេត្តកំពង់ឆ្នាំងភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់មានចំនួន ៦៨ ភាគរយ ខ្ពស់ជាងខេត្តបាត់ដំបងប្រហែល ១០ ភាគរយ និង ខ្ពស់ជាងខេត្តពោធិ៍សាត់ចំនួនប្រហែល ២០ ភាគរយ។ នៅក្នុងខេត្តកំពង់ឆ្នាំង ភាគរយគ្រួសារដែលមានទឹកស្អាតប្រើប្រាស់មានចំនួន ៤៣ភាគរយ នៅឆ្នាំ ២០០៨ បានកើនឡើងដល់ ៦៨ ភាគរយ នៅឆ្នាំ ២០១៩ ខណៈដែលខេត្តពោធិ៍សាត់ភាគរយគ្រួសារដែលមានទឹកស្អាតប្រើប្រាស់នៅឆ្នាំ ២០០៨ មានចំនួន ២៣ភាគរយ កើនឡើងដល់ ៤៨ ភាគរយ និង ខេត្តបាត់ដំបងនៅឆ្នាំ ២០០៨ មានចំនួន ៣២ភាគរយ កើនឡើងដល់៥៨ភាគរយនៅឆ្នាំ ២០១៩។ បើគិតជាមធ្យមនៅទូទាំងប្រទេស ភាគរយគ្រួសារ ដែលមានទឹកស្អាតប្រើប្រាស់បានកើនឡើងប្រហែលចំនួន ២៦ ភាគរយ ពីឆ្នាំ ២០០៨ ដល់ ២០១៩ និង ខេត្តទាំងបីក៏កើនឡើងប្រហាក់ប្រហែលចំនួននេះដែរ ពីឆ្នាំ ២០០៨ ដល់ ២០១៩។

រូបភាព ២.១៨ ភាគរយគ្រួសារមានទឹកស្អាតប្រើប្រាស់ នៅក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ឆ្នាំ ២០០៨ និង ២០១៩




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## ខ.ទឹកកខ្វក់

ផ្អែកតាមរបាយការណ៍ស្ថានភាពបរិស្ថានលើកទី ៣ ឆ្នាំ ២០១៩ បង្ហាញថា បរិមាណសំណល់រាវបញ្ចេញចោលនៅរាជធានីភ្នំពេញក្នុងឆ្នាំ ២០១៣ មានប្រមាណ១០៨.១៩៨.៧២៥ ម³/ឆ្នាំ គឺមានការកើនឡើងប្រមាណ ១៧.៨៩៨.៥៧៤ ម³/ឆ្នាំ បើប្រៀបធៀបឆ្នាំ ២០១២។ មានន័យថា ឆ្នាំ ២០១២ បរិមាណសំណល់រាវដែលបញ្ចេញចោលនៅរាជធានីភ្នំពេញ មាន ៩០.២៩៩.២៣៤ម³/ឆ្នាំ។ បរិមាណបញ្ចេញចោលនេះ មានការកើនឡើងជាប្រចាំពីមួយឆ្នាំទៅមួយឆ្នាំ ។ រូបភាព ២.១៩ បង្ហាញពីបរិមាណទឹកកខ្វក់នៅរាជធានីភ្នំពេញ ដែលបានបញ្ចេញចោលនៅក្នុងចន្លោះឆ្នាំ ២០០៦ ដល់ ២០១៧។

រូបភាព ២.១៩ បរិមាណទឹកកខ្វក់បញ្ចេញពីរាជធានីភ្នំពេញ ឆ្នាំ ២០០៦ ដល់ ២០១៧




ប្រភព: ក្រសួងបរិស្ថានឆ្នាំ ២០១៧

## ២.៣.៣ បង្គន់អនាម័យ

នៅក្នុងឆ្នាំ ១៩៩៨ ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ១២,៨ ភាគរយ បានកើ ៣៣,៧ ភាគរយ នៅឆ្នាំ ២០០៨ និងនៅឆ្នាំ ២០១៩ កើនឡើងដល់ ៨៣,៨ ភាគរយ ។បើគិតជាមធ្យមកំណើនគិតជាភាគរយគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ៧១ ភាគរយ បើគិតរវាងឆ្នាំ ១៩៩៨ និង ២០១៩ និង ៥០ ភាគរយ បើគិតរវាងឆ្នាំ ២០០៨ និង ២០១៩។

### រូបភាព ២.១៩ ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨
- លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

ផ្អែកតាមលទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩ បានបង្ហាញថា ចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ៨៤ ភាគរយ និងគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់មានចំនួន ១៦ ភាគរយ ខណៈដែលខេត្តកំពង់ឆ្នាំងចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ៧១ ភាគរយ និងគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់មានចំនួន ២៩ ភាគរយ ខេត្តពោធិ៍សាត់ចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ៧៨ ភាគរយ និងគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់មានចំនួន ២២ ភាគរយ និងខេត្តបាត់ដំបងចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួនប្រហែល ៩០ ភាគរយ និងគ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់មានចំនួនប្រហែល ១០ ភាគរយ។ ខេត្តកំពង់ឆ្នាំង និង ខេត្តពោធិ៍សាត់គ្រួសារដែលគ្មានបង្គន់អនាម័យមានចំនួនភាគរយច្រើនជាងទូទាំងប្រទេស ខណៈខេត្តបាត់ដំបងមានចំនួនតិចជាងទូទាំងប្រទេស។

រូបភាព ២.២០ ភាគរយចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់នៅឆ្នាំ ២០១៩




ប្រភព: - លទ្ធផលជំរឿនសរុបចុងក្រោយ ជំរឿនប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៩

## ២.៤ គ្រោះមហន្តរាយ

គ្រោះមហន្តរាយធម្មជាតិដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា គឺគ្រោះទឹកជំនន់ ខ្យល់ព្យុះ រន្ទះបាញ់ គ្រោះរាំងស្ងួត ការបាក់ច្រាំងទន្លេស្ទឹង ការបាក់រលំអគារ ឬ សំណង់ អគ្គីភ័យ និងជំងឺឆ្លងផ្សេងៗ ។ ផ្អែកតាមទិន្នន័យរបាយការណ៍ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៩ ខែ ឆ្នាំ ២០២០ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានបង្ហាញថា ចំនួនអ្នកស្លាប់ដោយសាររន្ទះបាញ់ បាក់រលំអគារ និង អគ្គិភ័យមានចំនួនច្រើនជាងគ្រោះមហន្តរាយទឹកជំនន់ ខ្យល់កន្ត្រាក់ និងការដួលរលំឧបករណ៍សាងសង់ផ្សេងៗ ដែលមានចំនួនសរុប ១៣៣ នាក់ ។ នៅក្នុងនោះអ្នកស្លាប់ដោយសាររន្ទះបាញ់មានចំនួន ៦២ នាក់ច្រើនជាងគេ បន្ទាប់មកការបាក់រលំអគារមានចំនួន ៣៦ នាក់ និង អគ្គិភ័យ មានចំនួន ២២ នាក់ ខណៈដែលអ្នកដែលស្លាប់ដោយសារទឹកជំនន់មានចំនួនតែ ៣ នាក់ ហើយខ្យល់កន្ត្រាក់ និងការដួលរលំឧបករណ៍សាងសង់មានចំនួន ៥ នាក់ ស្មើគ្នា នៅក្នុងរយៈពេល ៩ ខែ ក្នុងឆ្នាំ ២០២០។ គ្រោះថ្នាក់ស្លាប់ទាំងនេះ អាចបណ្តាលមកពីការពុំទទួលបានព័ត៌មានជូនដំណឹង ឬ អាចមកពីការធ្វេសប្រហែសផងដែរ។

## រូបភាព ២.២១ ចំនួនអ្នកស្លាប់តាមប្រភេទនៃគ្រោះមហន្តរាយ ឆ្នាំ ២០២០




ប្រភព៖ របាយការណ៍ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៩ ខែ ឆ្នាំ ២០២០
របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

នៅក្នុងសម័យថ្មីនេះ ជំងឺឆ្លងត្រូវបានគេចាត់ទុកជាគ្រោះមហន្តរាយមួយផងដែរ ដូចជា ជំងឺគ្រុនឈាម គ្រុនឈីក និងជំងឺកូវីដ១៩ ដែលកំពុងរាតត្បាតពាសពេញពិភពលោក ហើយពុំមានអ្នកស្លាប់សម្រាប់ប្រទេសកម្ពុជា ខណៈដែលនៅប្រទេសផ្សេងៗលើពិភពលោកមានអ្នកស្លាប់ជាច្រើនអ្នក ។

## រូបភាព ២.១៩ ចំនួនករណីជំងឺឆ្លង ឆ្នាំ ២០២០




ប្រភព៖ របាយការណ៍ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៩ ខែ ឆ្នាំ ២០២០
របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

ក្នុងចំណោមប្រភេទគ្រោះមហន្តរាយធម្មជាតិ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជានោះ ឆ្នាំ ២០១៧ គឺគ្រោះមហន្តរាយខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះរាំងស្ងួត បានធ្វើឲ្យប៉ះពាល់ដល់ការរស់នៅរបស់ប្រជាជនក្នុងការប្រកបរបររកស៊ីប្រចាំថ្ងៃ ។ គ្រោះរាំងស្ងួតបានកើតឡើងគឺធ្វើឲ្យប៉ះពាល់ដល់ចំនួនគ្រួសារ មានចំនួនច្រើនជាងគេរហូតដល់ ៥៧.៨១៦ គ្រួសារ សម្រាប់ទូទាំងប្រទេស តំបន់បឹងទន្លេសាបមានចំនួន៤១.១៧៥ គ្រួសារ និង ខេត្ត ៣ មានចំនួន ២.៥៥៣ គ្រួសារ។ គ្រោះទឹកជំនន់ជាប្រភេទគ្រោះមហន្តរាយលំដាប់លេខ ២ បន្ទាប់ពីគ្រោះរាំងស្ងួតដែលធ្វើឲ្យប៉ះពាល់ដល់ចំនួនគ្រួសារ ១៧.២១៣ គ្រួសារ សម្រាប់ទូទាំងប្រទេស តំបន់បឹងទន្លេសាបមានចំនួន ៣.៩៣៤ គ្រួសារ និង ខេត្ត ៣ មានចំនួន ៥០៥ គ្រួសារ ។ គ្រោះមហន្តរាយខ្យល់ព្យុះស្ថិតនៅក្នុងលំដាប់ទី ៣ គឺលំដាប់ចុងក្រោយបន្ទាប់ពីគ្រោះទឹកជំនន់ ដែលប៉ះពាល់ដល់គ្រួសារចំនួន ២.៥៨៤ គ្រួសារ សម្រាប់ទូទាំងប្រទេស តំបន់បឹងទន្លេសាប ១.៤៣០ គ្រួសារ និង ខេត្ត ៣ មានចំនួន ៤២២ គ្រួសារ។

**រូបភាព ២.២០ ចំនួនគ្រួសារដែលរងគ្រោះដោយគ្រោះមហន្តរាយបែងចែកតាមតំបន់ ឆ្នាំ ២០១៧**




ប្រភព: ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

គ្រោះមហន្តរាយបានបណ្ដាលឲ្យមនុស្សស្លាប់នៅទូទាំងប្រទេសឆ្នាំ ២០១៧ មានចំនួន ៤៤៣ នាក់ ដែលក្នុងនោះគ្រោះទឹកជំនន់បានបណ្ដាលឲ្យមនុស្សស្លាប់រហូតដល់ ២៦៤នាក់ រន្ទះបាញ់ ១៣៧ នាក់ និងខ្យល់ព្យុះមានចំនួនអ្នកស្លាប់ ៤២ នាក់ ។ នៅក្នុងតំបន់បឹងទន្លេសាបចំនួនមនុស្សស្លាប់សរុប ២០៥ នាក់ ដែលក្នុងនោះគ្រោះទឹកជំនន់បានបណ្ដាលឲ្យមនុស្សស្លាប់ចំនួន ១២៧ នាក់ ស្លាប់ដោយរន្ទះបាញ់ ៧១ នាក់ និង ស្លាប់ដោយខ្យល់ព្យុះមានចំនួន ៧ នាក់ និង ខេត្ត ៣ មានចំនួនអ្នកស្លាប់ដោយគ្រោះទឹកជំនន់មានចំនួន ២៨នាក់ រន្ទះបាញ់ ៣៣នាក់ និង ខ្យល់ព្យុះមានចំនួនអ្នកស្លាប់ ២ នាក់ ។

**រូបភាព ២.២១ ចំនួនអ្នកស្លាប់ដោយសារគ្រោះមហន្តរាយ ឆ្នាំ ២០១៧**




ប្រភពៈ ទិន្នន័យមូលដ្ឋាន (CDB) របស់មន្ទីរផែនការរាជធានី ខេត្តឆ្នាំ ២០១៧

## ២.៥ ការប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជាមានផ្ទៃដី ១៨១.០៣៥ គីឡូម៉ែត្រក្រឡា ស្ថិតនៅភាគនិរតីនៃឧបទ្វីបអាស៊ីបូព៌ា ហើយផ្ទៃដីប្រមាណ ២០ ភាគរយត្រូវបានប្រើប្រាស់សម្រាប់ដំណាំកសិកម្ម ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិកទាំងស្រុង និងស្ថិតនៅចំណុចខាងត្បូងច្រើនជាង ១០ អង្សានៅលើអេក្វាទ័រ។ សីតុណ្ហភាពអតិបរមាខ្ពស់ជាង ៣៣ អង្សាសេ ជាទូទៅចាប់ផ្តើមរដូវវស្សានៅខែមីនា និងខែមេសា ហើយអាចកើនឡើងដល់ ៣៨ អង្សាសេ។ សីតុណ្ហភាពអប្បបរមាធ្លាក់នៅក្រោម ១០ អង្សាសេ ។ នៅ ខែមករាជាខែត្រជាក់បំផុត និង ខែមេសាជាខែដែលក្តៅបំផុត។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំគឺរវាង ១៤២ និង ២០០ សង់ទីម៉ែត្រ ។ ភ្លៀងធ្លាក់ពីខែ មេសាដល់ខែកញ្ញាក្នុងតំបន់ដីទំនាបបឹងទន្លេសាប មេគង្គ ជាមធ្យមប្រចាំឆ្នាំពី ១១០ ទៅ ១៩០ សង់ទីម៉ែត្រ ប៉ុន្តែបរិមាណនេះប្រែប្រួលដែលគួរឲ្យកត់សំគាល់ពីមួយឆ្នាំទៅមួយឆ្នាំ ។ តែទោះបីយ៉ាងណាក៏ដោយ តំបន់ទឹកភ្លៀងដ៏ធំបំផុតនេះភាគច្រើនហូរទៅសមុទ្រ ហើយមានបរិមាណតិចតួចប៉ុណ្ណោះ ដែលហូរតាមស្ទឹងទន្លេចូលក្នុងបឹងទន្លេសាប។ សំណើមនៅប្រទេសកម្ពុជា គឺខ្ពស់នៅពេលយប់ពេញមួយឆ្នាំ និងនៅពេលរដូវប្រាំងសំណើមមធ្យមប្រមាណ ៥០ ភាគរយ ឬ ទាបជាងបន្តិច ប៉ុន្តែវាអាចមានប្រមាណ ៦០ ភាគរយ នៅរដូវវស្សា។

### ២.៥.១ ស្ថានភាពទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ ២០១០ ដល់ ២០១៧ មានធ្លាក់ចុះមក ពី ១.៥៨៣,៦ មីលីម៉ែត្រនៅឆ្នាំ ២០២១០ មកត្រឹម ១.៥០៦ មីលីម៉ែត្រនៅឆ្នាំ ២០១៧ ខណៈដែលនៅឆ្នាំ ២០១១ និងឆ្នាំ ២០១៣ មានលក្ខណៈប្រហាក់ប្រហែលគ្នាពីចន្លោះ ១,៧៦៧មីលីម៉ែត្រ ទៅ ១,៧៨១ មីលីម៉ែត្រ និងនៅក្នុងឆ្នាំ ២០១២ និងឆ្នាំ ២០១៤ មានលក្ខណៈប្រហាក់ប្រហែលគ្នាពីចន្លោះ ១.៦៣២ មីលីម៉ែត្រទៅ១.៦៦០ មីលីម៉ែត្រ។ ចំពោះស្ថានភាពទឹកភ្លៀងក្នុងខេត្តទាំង ៣ មានចំនួនទឹកភ្លៀងតិចជាងគេគឺខេត្តបាត់ដំបង ធៀបទៅនឹងទូទាំងប្រទេស និង ខេត្តពីរទៀតដែលបង្ហាញនៅក្នុង រូបភាព ២.២១ ។ ស្ថានភាពទឹកភ្លៀងនៅទូទាំងប្រទេស និង នៅខេត្តទាំង ៣ មានការធ្លាក់ចុះខ្លាំងនៅឆ្នាំ ២០១៥ មានន័យថា មានភ្លៀងធ្លាក់តិច ហើយចាប់ពីឆ្នាំ ២០១៦ មានភ្លៀងច្រើនបន្តិច និងចំនួនទឹកភ្លៀងបានធ្លាក់ចុះនៅឆ្នាំ ២០១៧ លើកលែងតែខេត្តបាត់ដំបងមានស្ថានភាពកើឡើងវិញ។

### រូបភាព ២.២២ កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ តាមស្ថានីយ៍គិតជាមីលីម៉ែត្រ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

និន្នាការនៃចំនួនថ្ងៃមានភ្លៀងធ្លាក់ជាមធ្យម បើពិនិត្យជារួមសម្រាប់នៅទូទាំងប្រទេសមានការថយចុះ ហើយនិន្នាការនៃចំនួនថ្ងៃមានភ្លៀងធ្លាក់នៅក្នុងខេត្តបាត់ដំបង និងសៀមរាបមានស្ថានភាពដូចនៅទូទាំងប្រទេសដែរ ប៉ុន្តែខេត្តបន្ទាយមានជ័យមាននិន្នាការកើនឡើងខុសពីស្ថានភាពនៅទូទាំងប្រទេស និងខេត្តទាំងពីរខាងលើ។ និន្នាការចំនួនថ្ងៃមានភ្លៀងធ្លាក់ជាមធ្យមនៅទូទាំងប្រទេសមានការកើនឡើងនៅក្នុងឆ្នាំ ២០១១ និង ២០១២ ហើយបន្តធ្លាក់ចុះរហូតដល់ឆ្នាំ ២០១៥ ខណៈដែលខេត្តបាត់ដំបងបានកើនឡើងបន្តិចនៅឆ្នាំ ២០១៣ ហើយបានធ្លាក់ចុះនៅឆ្នាំ ២០១៤ និងនៅឆ្នាំ ២០១៥ រក្សាស្ថានភាពដដែល និងខេត្តសៀមរាបបានថយចុះនៅឆ្នាំ ២០១៣ ហើយបានកើនឡើងនៅឆ្នាំ ២០១៤ និងបានធ្លាក់ចុះនៅឆ្នាំ ២០១៥។ ចំណែកឯខេត្តបន្ទាយមានជ័យបានកើនឡើងខ្ពស់នៅឆ្នាំ ២០១១ និង ២០១២ និងបានធ្លាក់ចុះបន្តិចនៅឆ្នាំ ២០១៣ ហើយបានកើនឡើងចាប់ពីឆ្នាំ ២០១៤។

### រូបភាព ២.២៣ ចំនួនថ្ងៃមានភ្លៀងក្នុងឆ្នាំគិតជាមធ្យមតាមស្ថានីយ៍




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

## ២.៥.២ សីតុណ្ហភាព

តារាង ២.៥ បង្ហាញអំពី សីតុណ្ហភាពអប្បបរមានិងអតិបរិមាគិតជាអង្សាសេតាមខេត្តមួយចំនួន ដែលមានស្ថានីយ៍វាស់ស្ទង់សីតុណ្ហភាព។ តាមទិន្នន័យក្នុងតារាង ឃើញថាសីតុណ្ហភាពអប្បបរមាគិតជាមធ្យមរយៈពេល ៧ ឆ្នាំ មានចំនួន១៩,៦ អង្សាសេ ខ្ពស់ជាងខេត្តប៉ៃលិន ពោធិ៍សាត់ និង ខេត្តបន្ទាយមានជ័យ ប៉ុន្តែស្មើនឹងខេត្តសៀមរាប និងទាបជាងខេត្តបាត់ដំបង។ ក្នុងចំណោមខេត្ត ៦ ខាងក្រោម ខេត្តប៉ៃលិនមានសីតុណ្ហភាពអប្បរមាទាបជាងគេ និងខេត្តបាត់ដំបងខ្ពស់ជាងគេ បើគិតជាមធ្យមពីឆ្នាំ ២០១១ ដល់២០១៧។ ចំពោះសីតុណ្ហភាពអតិបរិមាគិតជាមធ្យមទូទាំងប្រទេសមានចំនួន ៣៥,៩ អង្សាសេ ខ្ពស់ជាងខេត្តបន្ទាយមានជ័យ និងទាបជាងខេត្ត ៥ ដទៃទៀត។

## តារាង ២.៥ សីតុណ្ហភាព អប្បបរមានិងអតិបរិមា តាមស្ថានីយ៍ គិតជាអង្សាសេ

| ខេត្ត | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | គិតមធ្យម រយៈពេល៧ឆ្នាំ |
|---|---|---|---|---|---|---|---|---|
| | | | | អប្បបរមា | | | | |
| បន្ទាយមានជ័យ | 19.7 | 20.7 | 24.1 | 20.0 | 21.8 | 13 | 14 | 19.0 |
| បាត់ដំបង | 21.3 | 22.0 | 22.0 | 26.6 | 22.1 | 13 | 14 | 20.1 |
| កំពង់ធំ | 20.4 | 22.8 | 22.5 | 21.7 | 22.1 | 15 | 15 | 19.9 |
| ពោធិ៍សាត់ | 20.7 | 21.6 | 21.1 | 21.7 | 21.9 | 12 | 14 | 19.0 |
| សៀមរាប | 20.4 | 22.7 | 22.1 | 21.9 | 22.0 | 13 | 15 | 19.6 |
| ប៉ៃលិន | 20.7 | 20.5 | 18.1 | 18.8 | 18.8 | 12 | 14 | 17.6 |
| **ទូទាំងប្រទេស** | **20.8** | **20.9** | **21.8** | **21.9** | **22.1** | **15.5** | **14.48** | **19.6** |
| | | | | អតិបរមា | | | | |
| បន្ទាយមានជ័យ | 36.2 | 34.4 | 24.1 | 34.6 | 36.2 | 41 | 37 | 34.8 |
| បាត់ដំបង | 34.5 | 36.1 | 36.2 | 36.3 | 36.2 | 41 | 38 | 36.9 |
| កំពង់ធំ | 31.7 | 34.6 | 33.2 | 33.3 | 35.8 | 42 | 36 | 35.2 |
| ពោធិ៍សាត់ | 35.3 | 36.1 | 36.2 | 36.2 | 37 | 41 | 37 | 37.0 |
| សៀមរាប | 34.7 | 33.4 | 36.3 | 35.7 | 36.1 | 41 | 36 | 36.2 |
| ប៉ៃលិន | 34.5 | 35.4 | 35 | 36.75 | 36.7 | 40 | 37 | 36.5 |
| **ទូទាំងប្រទេស** | **34.5** | **35.1** | **34.2** | **35.0** | **35.9** | **40.16** | **36.44** | **35.9** |

ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

រូបភាព ២.២៣ បង្ហាញអំពីនិន្នាការនៃសីតុណ្ហភាពអតិបរិមា និងអប្បបរមា នៅទូទាំងប្រទេស តាមស្ថានីយ៍គិតជាអង្សាសេ ។ ពិនិត្យជារួមនិន្នាការសីតុណ្ហភាពអតិបរិមាពីឆ្នាំ ២០១៥ ដល់ ២០១៧ មានការប្រែប្រួលដោយមានសីតុណ្ហភាពខ្ពស់ជាង ៣៥ អង្សាសេ ខណៈពីឆ្នាំ ២០១១ ដល់ ២០១៤ សីតុណ្ហភាពអតិបរិមាប្រហែល ៣៥អង្សាសេ។ ចំពោះសីតុណ្ហភាពអប្បរមា ពីឆ្នាំ ២០១១ ដល់ ២០១៥ ស្ថិតក្នុងសីតុណ្ហភាពខ្ពស់ជាង ២០ អង្សាសេបន្តិច តែនៅឆ្នាំ ២០១៦ ត្រជាក់ខ្លាំងធ្លាក់ដល់ ១៥ អង្សាសេ និង ឆ្នាំ ២០១៧ កើនឡើងត្រឹម ២០ អង្សាសេទាបជាងឆ្នាំ ២០១១ ដល់ ២០១៥។

**រូបភាព ២.២៣ សីតុណ្ហភាពអតិបរិមា និងអប្បបរមា ទូទាំងប្រទេស តាមស្ថានីយ៍ គិតជាអង្សាសេ**




ប្រភព: នាយកដ្ឋានឧតុនិយម ក្រសួងធនធានទឹក និង ឧតុនិយម

## ២.៥.៣ កម្ពស់ទឹក

នៅក្នុងរូបភាព ២.២៤ បង្ហាញអំពីស្ថានភាពទូទៅនៃកម្ពស់ទឹកអតិបរមានៅទន្លេមេគង្គគិតជាម៉ែត្រពីឆ្នាំ ១៩៩០ ដល់ ២០១៧តាមស្ថានីយដែលរួមមាន ស្ទឹងត្រែង ក្រចេះ កំពង់ចាម និង បាសាក់មាននិន្នាការប្រែប្រួលគួរឲ្យកត់សំកាល់បើគិតពីឆ្នាំ ១៩៩០ មកទល់ឆ្នាំ ២០១៧ មក។ កម្ពស់ទឹកនៅក្នុងឆ្នាំ ២០១៧ ទាបជាងឆ្នាំ កន្លងទៅ ហើយនៅឆ្នាំ ខណៈដែលឆ្នាំ ២០១៦ កាន់តែទាបជាងឆ្នាំកន្លងទៅ ខ្លាំងមកត្រឹម ១០,១ ម៉ែត្រ ។ រូបភាព ២.២៥ បង្ហាញពីស្ថានភាពកម្ពស់ទឹកអប្បបរមានៅទន្លេមេគង្គពីឆ្នាំ ២០១១ ដល់ ២០១៧ បានបង្ហាញថាកម្ពស់ទឹកមានបរិមាណទាបខ្លាំងនៅឆ្នាំ ២០១៥ និងឆ្នាំ២០១៦ ខណៈដែល ឆ្នាំ ២០១៧ កើនឡើងប្រហាក់ប្រហែលឆ្នាំ២០១២ និងឆ្នាំ ២០១៣។

## រូបភាព ២.២៤ កំពស់ទឹកជាអតិបរមានៅទន្លេមេគង្គ គិតជាម៉ែត្រ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

## រូបភាព ២.២៥ កំពស់ទឹកជាអប្បបរមានៅទន្លេមេគង្គ គិតជាម៉ែត្រ




ប្រភព: នាយកដ្ឋានឧត្តុនិយម ក្រសួងធនធានទឹក និង ឧត្តុនិយម

# ជំពូក ៣
# ការវិភាគលទ្ធផល

## ៣.១ ព័ត៌មានទូទៅ
### ៣.១.១ គ្រួសារ

នៅក្នុងការចុះសម្ភាសន៍ស្រង់ទិន្នន័យជាក់ស្តែងនៅក្នុងខេត្តទាំង ៣ សម្រាប់តំបន់ដែលជាប់បឹងទន្លេសាប តារាងបញ្ជីសំណួរ ២ ត្រូវបានប្រើប្រាស់មានតារាងបញ្ជីសំណួរសម្រាប់សួរទៅមេភូមិនូវព័ត៌មាននៅក្នុងភូមិទាំងមូល និងតារាងបញ្ជីសំណួរសម្រាប់សួរមេគ្រួសារ គឺសម្ភាសន៍មេគ្រួសារផ្ទាល់។

តារាង ៣.១ បង្ហាញអំពីចំនួនគ្រួសារប្រជាជនទាំង ៩ ភូមិ នៅក្នុងខេត្តគោលដៅទាំង ៣ ដែលបានសម្ភាសន៍មេភូមិទាំង ៩ នាក់។ ចំនួនគ្រួសារប្រជាជនពិនិត្យជារួមក្នុងខេត្តទាំង ៣ មានការកើនឡើងចំនួន ២.៩២៨គ្រួសារ ពីឆ្នាំ ២០១៦ ដល់ ៣.៣៣៣ គ្រួសារ នៅឆ្នាំ ២០២០ ប៉ុន្តែបើពិនិត្យខេត្តកំពង់ឆ្នាំងមានការថយចុះ ហើយខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងមានការកើនឡើង។ តែទោះបីយ៉ាងណាក៏ដោយ ចំនួនគ្រួសារសរុបនៅក្នុខេត្តតាំង ៣ មានការកើនឡើងជាបន្តបន្ទាប់ ។

**តារាង ៣.១ ចំនួនគ្រួសារសរុបនៅក្នុងភូមិគោលដៅតាមបណ្តាខេត្តចុះសម្ភាសន៍**

| លេខរៀង | ខេត្ត | ចំនួនគ្រួសារ | | | | |
|---|---|---|---|---|---|---|
| | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
| ១ | កំពង់ឆ្នាំង | 897 | 918 | 791 | 693 | 766 |
| ២ | ពោធិ៍សាត់ | 802 | 837 | 899 | 878 | 932 |
| ៣ | បាត់ដំបង | 1,229 | 1,266 | 1,331 | 1,624 | 1,635 |
| សរុប | | 2,928 | 3,021 | 3,021 | 3,195 | 3,333 |

តារាង ៣.២ បង្ហាញតួលេខចំនួនគ្រួសារបែងចែកតាមក្រុមអាយុក្នុងចំណោមមេគ្រួសារទាំង ៩០០ នាក់ ដែលបានចុះសម្ភាសន៍ផ្ទាល់នៅក្នុងភូមិគោលដៅ ។ តាមតួលេខ ចំនួនតួលេខមេគ្រួសារក្រុមអាយុពី៤០ ដល់ ៥៩ ឆ្នាំ មានចំនួន ៤០៤ នាក់ (៤៥%) មេគ្រួសារស្ថិតក្នុងក្រុមអាយុ ១៥ ដល់ ៣៩ ឆ្នាំ មានចំនួន ៣៣៥ នាក់ (៣៧%) និង មេគ្រួសារស្ថិតក្នុងក្រុមអាយុ ៦០ឆ្នាំ ឡើងមានចំនួន ១៦១នាក់ (១៨%) បើប្រៀបធៀបទៅនឹងចំនួនមេគ្រួសារសរុប។ មេគ្រួសារភាគច្រើនជាបុរសមានចំនួន ៦៩១ នាក់ (៧៧%) និង មេគ្រួសារជាស្ត្រីមានចំនួន ២០៩ នាក់ (២៣%)។

តារាង ៣.២ ចំនួនមេគ្រួសារ បែងចែកតាមក្រុមអាយុ

| ក្រុមអាយុ | ភេទមេគ្រួសារ | | |
|---|---|---|---|
| | ប្រុស | ស្រី | ទាំងពីរភេទ |
| ១៥ ដល់ ៣៩ឆ្នាំ | 280 | 55 | 335 |
| ៤០ ដល់ ៥៩ឆ្នាំ | 310 | 94 | 404 |
| ៦០ឆ្នាំ ឡើង | 101 | 60 | 161 |
| សរុប | 691 | 209 | 900 |

## ៣.១.២ ទំហំគ្រួសារ

រូបភាព ៣.១ បង្ហាញថា ចំនួនសមាជិកគ្រួសារជាមធ្យម ផ្អែកតាមលទ្ធផលចុងក្រោយ ជំរឿនទូទៅប្រជាជនឆ្នាំ ១៩៩៨ ឆ្នាំ ២០០៨ និង ឆ្នាំ ២០១៩ មាននិន្នាការជារួមធ្លាក់ចុះសម្រាប់ខេត្តទាំង ៣ និងទូទាំងប្រទេសពីជាង ៥នាក់ក្នុងមួយគ្រួសារមកជាង ៤នាក់ក្នុងមួយគ្រួសារ។ ការធ្លាក់ចុះនេះអាចបណ្តាលមកពីអត្រាកំណើតធ្លាក់ចុះ ទាំងនៅថ្នាក់ខេត្ត និងនៅថ្នាក់ជាតិ ដែលផ្អែកលើការយល់ដឹងអំពីគោលនយោបាយផែនការគ្រួសារ។

រូបភាព ៣.១ បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យមឆ្នាំ ១៩៩៨, ២០០៨ និង ឆ្នាម ២០១៩




ប្រភព៖ លទ្ធផលចុងក្រោយ នៃជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ ១៩៩៨ ឆ្នាំ២០០៨ និង ឆ្នាំ ២០១៩

រូបភាព ៣.២បង្ហាញថា ចំនួនសមាជិកគ្រួសារជាមធ្យម ផ្អែកតាមលទ្ធផលនៃការចុះសម្ភាសន៍ស្រង់ទិន្នន័យនៃខេត្តទាំង ៣ នៅឆ្នាំ ២០២០ បង្ហាញថា ចំនួនសមាជិកគ្រួសារជាមធ្យមក្នុងមួយគ្រួសារមានចំនួន ៤,៨ នាក់ក្នុងមួយគ្រួសារគិតជាមធ្យមក្នុងខេត្តទាំង ៣ ។ សម្រាប់ខេត្តកំពង់ឆ្នាំងសមាជិកគ្រួសារជាមធ្យមមានចំនួន ៤,៣ ទាបជាងគេក្នុងចំណោមខេត្តទាំង ៣ ហើយខេត្តពោធិ៍សាត់មានសមាជិកគិតជាមធ្យមចំនួន ៥,៣ នាក់នៅក្នុងមួយគ្រួសារ ខណៈដែលខេត្តបាត់ដំបងមានសមាជិកគិតជាមធ្យមចំនួន ៤,៩ នាក់នៅក្នុងមួយគ្រួសារ។

**រូបភាព ៣.២ បង្ហាញអំពីចំនួនសមាជិកគ្រួសារគិតជាមធ្យម ឆ្នាំ ២០២០ (ការសម្ភាសន៍ជាក់ស្តែង)**




### ៣.១.៣ ចំណាកស្រុក

ទិន្នន័យនៅក្នុង តារាង ៣.៣ បង្ហាញថា ចំនួនប្រជាជន ២៣៧ នាក់ ស្មើនឹង ៥,៨ភាគរយ នៅក្នុងចំណោមប្រជាជន ៤.០៩១ នាក់ ដែលបានធ្វើចំណាកស្រុកទាំងក្នុង និងក្រៅប្រទេស ដែលនៅក្នុងនោះចំនួនប្រជាជន ១៧៦នាក់ (៤,៣%) បានធ្វើចំណាកស្រុកក្នុងប្រទេស និង ចំនួនប្រជាជន ៦១ នាក់ (១,៥%) បានធ្វើចំណាកស្រុកទៅក្រៅប្រទេស។ នៅក្នុងចំនួនប្រជាជនដែលបានធ្វើចំណាកស្រុក គឺចំនួនសមាជិកភេទប្រុស ដែលបានធ្វើចំណាកស្រុកមានចំនួន ១១២នាក់ (៥,៧%) និង ភេទស្រីមាន ១២៥នាក់ (៥,៩%) ។

តារាង ៣.៣ ចំនួនសមាជិកអចិន្ត្រៃយ៍ និង សមាជិកចំណាកស្រុក

| អធិប្បាយ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| **សមាជិកអចិន្ត្រៃយ៍** | 1,957 | 2,134 | 4,091 |
| **សមាជិកចំណាកស្រុក** | 112 | 125 | 237 |
| សមាជិកចំណាកស្រុកក្នុងប្រទេស | 76 | 100 | 176 |
| សមាជិកចំណាកស្រុកក្រៅប្រទេស | 36 | 25 | 61 |

រូបភាព ៣.៣ បង្ហាញថា ភាគរយសមាជិកគ្រួសារដែលបានធ្វើចំណាកស្រុកក្នុងប្រទេសភេទប្រុសមានចំនួន ៦៨ ភាគរយ ខណៈដែលការធ្វើចំណាកស្រុកទៅក្រៅប្រទេសមានតែ ៣២ ភាគរយ ។ ចំណែកឯសមាជិកគ្រួសារភេទស្រី ដែលបានធ្វើចំណាកស្រុកនៅក្នុងប្រទេសមានចំនួនច្រើនជាងសមាជិកគ្រួសារភេទប្រុសមានចំនួន ៨០ភាគរយ និងធ្វើចំណាកស្រុកក្រៅប្រទេសមានចំនួន ២០ភាគរយតិចជាងបុរស។

**រូបភាព ៣.៣ ភាគរយសមាជិកគ្រួសារធ្វើចំណាកស្រុកចែកតាមភេទ**



## គ.ចំណាកស្រុកក្នុងប្រទេស

ការធ្វើចំណាកស្រុកសំដៅការផ្លាស់ប្តូរទីលំនៅដ្ឋានពីភូមិមួយទៅភូមិមួយទៀត បើទោះបីនៅក្នុងខេត្តតែមួយក៏ដោយ។ ទិន្នន័យក្នុងរូបភាព ៣.៤ បានបង្ហាញថា រាជធានីខេត្តដែលមានសមាជិកគ្រួសារបានធ្វើ ចំណាកស្រុកពីខេត្តផ្សេងចូលទៅក្នុង ២៥ រាជធានីខេត្តក្នុងព្រះរាជាចក្រកម្ពុជា គឺភាគរយដែលខ្ពស់ជាងគេ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ បាត់ដំបង ព្រះសីហនុ កំពង់ឆ្នាំង និងខេត្តដទៃទៀតមានចំនួនតិចបំផុត ខណៈដែលខេត្តមិនបានរៀបរាប់ពុំមានសមាជិកគ្រួសារធ្វើចំណាកស្រុក។

**រូបភាព ៣.៤ ចំនួនសមាជិកគ្រួសារបានធ្វើចំណាកស្រុកតាមបណ្តាខេត្ត**




## គ១.មូលហេតុនៃចំណាកស្រុកក្នុងប្រទេស

រូបភាព ៣.៥ បង្ហាញអំពីមូលហេតុដែលសមាជិកនៅក្នុងគ្រួសារបានធ្វើចំណាកស្រុកទៅតាមរាជធានីខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទិន្នន័យនេះ បានបង្ហាញថា ចំនួនសមាជិកបានធ្វើចំណាកស្រុក ដោយសារតែការស្វែងរកការងារធ្វើមានចំនួនច្រើនជាងគេមានចំនួន ១៦៨នាក់ (៩៥,៥%) ក្នុងចំណោមមូលហេតុនៃការចំណាកស្រុកក្នុងប្រទេស ខណៈដែលការអប់រំ និង ប្តូរទីកន្លែងការងារមាចំនួនស្មើគ្នា។

រូបភាព ៣.៥ ភាគរយសមាជិកចំណាកស្រុកក្នុងប្រទេសតាមមូលហេតុ




## ខ.ចំណាកស្រុកក្រៅប្រទេស

រូបភាព ៣.៦ បង្ហាញថា ចំនួនសមាជិកដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃមានចំនួន ៥១ នាក់ (៨៣,៦%) ក្នុងចំណោមចំនួនសមាជិកចំណាកស្រុកក្រៅប្រទេសសរុប ៦១ នាក់ ហើយបន្ទាប់មកប្រទេសកូរ៉េខាងត្បូង មានចំនួន ៤នាក់ (៦,៦%) ស្មើនឹងប្រទេសជប៉ុន ៤នាក់ (៦,៦%) និងប្រទេសម៉ាឡេស៊ី ២នាក់ (៣,៣%) ។

រូបភាព ៣.៦ ចំនួនសមាជិកចំណាកស្រុកក្រៅប្រទេសតាមប្រទេស



### ១១.មូលហេតុនៃចំណាកស្រុកទៅក្រៅប្រទេស

រូបភាព ៣.៧ បង្ហាញថាចំនួនសមាជិកបានធ្វើចំណាកស្រុកដោយសារតែស្វែងរកការងារធ្វើ មានចំនួន ៦០ នាក់ (៩៨,៤%) និង មូលទៅបន្តការសិក្សាមាន ចំនួន ១នាក់ (១,៦%) ក្នុងចំណោមចំនួនសមាជិកដែលបានធ្វើចំណាកស្រុកក្រៅប្រទេសសរុប៦១នាក់ ហើយក្រៅពីនោះពុំមានមូលហេតុផ្សេងទេ។ ក្នុងចំណោមប្រជាជនចំណាកស្រុកក្រៅប្រទេសដោយមូលហេតុស្វែងរកការងារធ្វើ បុរសមានចំនួនប្រហែល ៥៨ ភាគរយ ច្រើនជាងស្ត្រីដែលមានចំនួនប្រហែល ៤២ភាគរយ។

រូបភាព ៣.៧ ភាគរយសមាជិកចំណាកស្រុកដោយមូលហេតុស្វែងរកការងារធ្វើ




### ៣.១.៤ ការចូលរួមកម្លាំងពលកម្ម

#### ក. វិស័យសេដ្ឋកិច្ច

តារាង ៣.៤ បង្ហាញអំពីការចូលរួមកម្លាំងពលកម្មរបស់សមាជិកគ្រួសារទៅតាមវិស័យសេដ្ឋកិច្ច នៅខេត្តគោលដៅនីមួយៗ សរុបមានចំនួន ២.១៦៨ នាក់ ក្នុងចំណោមប្រជាជនសរុប ៤.០៩១នាក់ ។ ក្នុងនោះអ្នកធ្វើការកសិកម្មមានចំនួនច្រើនជាងគេជាពិសេសការដំណាំ បន្ទាប់មកវិស័យសេវាកម្ម ៦៦៣នាក់ និង វិស័យសេវាកម្ម ១១៦នាក់ ។ រូបភាព ៣.៨ បង្ហាញអំពីភាគរយអ្នកធ្វើការក្នុងវិស័យសេដ្ឋកិច្ច ដែលក្នុងនោះវិស័យកសិកម្មមានចំនួន ៦៤,១ភាគ វិស័យឧស្សាហកម្ម ៥,៤ភាគរយ និង វិស័យសេវាកម្ម មានចំនួន ៣០,៥ភាគរយ។

តារាង ៣.៤ ចំនួនសមាជិកធ្វើការតាមវិស័យសេដ្ឋកិច្ច

| តាមវិស័យសេដ្ឋកិច្ច | ប្រុស | ស្រី | សរុប |
|---|---|---|---|
| ដាំដំណាំ | 677 | 616 | 1,293 |
| នេសាទ | 74 | 22 | 96 |
| ឧស្សាហកម្ម | 40 | 76 | 116 |
| សេវាកម្ម | 339 | 324 | 663 |
| សរុប | 1,130 | 1,038 | 2,168 |

រូបភាព ៣.៨ ភាគរយការចូលរួមកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ច




## គ. ផ្នែកការងារ

តារាង ៣.៥ បង្ហាញពីចំនួនសមាជិកគ្រួសារដែលបានចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ។ ទិន្នន័យនេះ ឃើញថាសមាជិកភាគច្រើនលើសលប់ បានចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យឯកជនប្រហែល ៩៧ ភាគរយ ទាំងផ្នែកឯកជនខ្មែរ និងផ្នែកឯកជនបរទេស នៅក្នុងនោះផ្នែកឯកជនខ្មែរមានចំនួន ១.៩៤៥នាក់ (៩០%) និងផ្នែកឯកជនបរទេស ១៥០នាក់ (៧%) ខណៈដែលការងារផ្នែករដ្ឋាភិបាលមានត្រឹមតែ ៦៧ នាក់ (៣,១%) និងផ្នែកការងារដទៃទៀតមានចំនួនតិចតួច។

តារាង ៣.៥ ចំនួនសមាជិកគ្រួសារចូលរួមកម្លាំងពលកម្មតាមផ្នែកការងារ

| ផ្នែកការងារ | ប្រុស | ស្រី | សរុប |
|---|---|---|---|
| រាជរដ្ឋាភិបាល | 45 | 22 | 67 |
| ផ្នែកឯកជនខ្មែរ | 996 | 949 | 1,945 |
| ផ្នែកឯកជនបរទេស | 55 | 95 | 150 |
| ផ្សេងៗ | 3 | 3 | 6 |
| សរុប | 1,099 | 1,069 | 2,168 |

រូបភាព ៣.៩ ភាគរយសមាជិកគ្រួសារធ្វើការតាមផ្នែកនៃការងារ




## ៣.២ បរិស្ថាន

### ៣.២.១ បង្គន់អនាម័យ

រូបភាព ៣.១០ បង្ហាញអំពីភាគរយគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យប្រើប្រាស់ឆ្នាំ ២០១៩ និង ២០២០ តាមរយៈការធ្វើសម្ភាសន៍ផ្ទាល់ ។ តាមទិន្នន័យនេះបង្ហាញថា គ្រួសារប្រជាជនដែលមានបង្គន់អនាម័យប្រើប្រាស់មានចំនួន ៥២ភាគរយនៅឆ្នាំ ២០១៩ និង បានកើនឡើងដល់ ៥៥ភាគរយនៅឆ្នាំ ២០២០។

រូបភាព ៣.១០ ភាគរយគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ






## ៣.២.២ សេវាប្រមូលសំរាម ទីតាំងទុកដាក់សំរាម និងផលប៉ះពាល់ពីការចោលសំរាម

រូបភាព ៣.១១ បង្ហាញអំពីចំនួនគ្រួសារមានសេវាប្រមូលសំរាម ទីតាំងចាក់សំរាម និងទទួលរងផលប៉ះពាល់ពីការចាក់សំរាម ។ តាមទិន្នន័យនេះបង្ហាញថា ទិន្នន័យជារួមនៅក្នុងឆ្នាំ២០១៩ និង ២០២០ មានលក្ខណៈប្រហាក់ប្រហែលគ្នា គឺខុសគ្នាតិចតួច។ សេវាកម្មប្រមូលសំរាមមានចំនួនក្រោម ១០ ភាគរយ នៅឆ្នាំ ២០១៩ និង ២០២០ ខណៈដែលទីតាំងនៃការចោលសំរាមមានការកើនឡើងជាង ១២ភាគរយបន្តិច នៅឆ្នាំ ទាំងពីរនេះ ហើយគ្រួសារដែលមានទីតាំងដាក់សំរាមនៅក្នុងផ្ទះមានចំនួនជិត ៥០ភាគរយ និងផលប៉ះពាល់ពីការចាក់សំរាមមានជាង១១ភាគរយបន្តិចនៅឆ្នាំ ២០១៩ និង ឆ្នាំ ២០២០ មានចំនួន ១១ ភាគរយ។

**រូបភាព ៣.១១ ភាគរយគ្រួសារមានសេវាប្រមូលសំរាម ទីតាំងចាក់សំរាម និងទទួលរងផលប៉ះពាល់ពីការចាក់សំរាម**



### ៣.២.៣ ផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្មឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត

រូបភាព ៣.១២ បង្ហាញឲ្យឃើញថា ភាគរយគ្រួសារផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្ម ឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត។ទិន្នន័យនេះ បង្ហាញថា គ្រួសារទទួលរងផលប៉ះពាល់ច្រើនមកពីការប្រើប្រាស់ជីគីមី និបាញ់ថ្នាំសម្លាប់សត្វល្អិតទាំងឆ្នាំ ២០១៩ និងឆ្នាំ ២០២០ មានជាង២០ ភាគរយ ខណៈផលប៉ះពាល់ផ្សេងទៀតមានក្រោម ១ភាគរយប៉ុណ្ណោះ ។

រូបភាព ៣.១២ ភាគរយគ្រួសារទទួលរងផលប៉ះពាល់ពីកាកសំណល់រោងសិប្បកម្មឬរោងចក្រ ការបង្ហូរកាកសំណល់ចូលក្នុងទឹក និងការបាញ់ថ្នាំសម្លាប់សត្វល្អិត។




### ៣.៣ គ្រោះមហន្តរាយ

គ្រោះមហន្តរាយគឺសំដៅទៅលើគ្រោះមហន្តរាយកើតឡើងដោយធម្មជាតិមានដូចជា ខ្យល់ព្យុះ រន្ទះបាញ់ ទឹកជំនន់ គ្រោះរាំងស្ងួត បាក់ច្រាំងទន្លេ ឬ ស្ទឹង ព្រែកជាដើម។ រូបភាព ៣.១៣ បង្ហាញថា គ្រួសារដែលទទួលគ្រោះមហន្តរាយក្នុងចំណោមគ្រួសារទាំង ៩០០ គ្រួសារ ។ ទិន្នន័យបង្ហាញថា ៦៥២គ្រួសារ (៧២ភាគរយ) ទទួលរងគ្រោះមហន្តរាយ និង ២៤៨ គ្រួសារ (២៨ភាគរយ) មិនទទួលរងគ្រោះមហន្តរាយ ។

### រូបភាព ៣.១៣ ភាគរយគ្រួសារដែលទទួលគ្រោះមហន្តរាយនៅឆ្នាំ ២០២០ ក្នុងភូមិគោលដៅ




រូបភាព ៣.១៤បង្ហាញថា ព័ត៌មានដែលទទួលបានតាមរយៈការផ្សាយទូរទស្សន៍ មានចំនួនប្រហែល ៦៦ ភាគរយ និងទទួលបានតាមរយៈអាជ្ញាធរមូលដ្ឋានមានចំនួន ២៣ ភាគរយ ហើយតាមទូរស័ព្ទដៃ មានចំនួនច្រើនជាង ២០ភាគរយបន្តិច ខណៈដែលក្រៅពីនោះមានចំនួនតិចជាង ២០ ភាគរយ ។

### រូបភាព ៣.១៤ ភាគរយគ្រួសារដែលទទួលបានប្រភពព័ត៌មាននៃគ្រោះមហន្តរាយ



តារាង ៣.៦ និង រូបភាព ៣.១៥ បង្ហាញថា ចំនួនគ្រួសារទទួលរងគ្រោះដោយសារគ្រោះរាំងស្ងួតមានចំនួនច្រើនជាងគេ ដែលមានចំនួនគ្រួសារប្រជាជន ៤៦០ គ្រួសារក្នុងចំណោម ៩០០ គ្រួសារ បន្ទាប់មកគ្រោះទឹកជំនន់ មាន៦៤ គ្រួសារ និង ខ្យល់ព្យុះមានចំនួន ៥៧ គ្រួសារក្នុងចំណោម ៩០០ គ្រួសារតាមប្រភេទនៃគ្រោះមហន្តរាយនីមួយៗ។

**តារាង ៣.៦ ចំនួនគ្រួសារទទួលរងគ្រោះតាមប្រភេទគ្រោះមហន្តរាយ**

| ប្រភេទគ្រោះមហន្តរាយ | ចំនួនគ្រួសារ | ភាគរយ |
|---|---|---|
| ខ្យល់ព្យុះ | 57 | 6.3 |
| ទឹកជំនន់ | 64 | 7.1 |
| រាំងស្ងួត | 460 | 51.1 |
| បាក់ច្រាំងទន្លេ | 21 | 2.3 |

**រូបភាព ៣.១៥ ភាគរយគ្រួសារទទួលរងគ្រោះមហន្តរាយតាមប្រភេទគ្រោះមហន្តរាយ**



## ៣.៤ ការប្រែប្រួលអាកាសធាតុ
### ៣.៤.១ ស្ថានភាពទឹកភ្លៀង

រូបភាព ៣.១៧ បង្ហាញឲ្យឃើញថា ស្ថានភាពភ្លៀងធ្លាក់តាមការចំណាំរបស់ប្រជាជនដែលបានផ្តល់ចម្លើយអំឡុងពេលសម្ភាសន៍គឺ មានចំនួនមេគ្រួសារ ៧៤៥ នាក់ (៨២,៨%) បានឆ្លើយថាមានមិនភ្លៀងទៀងទាត់ ហើយមានចំនួនមេគ្រួសារ ៨៦ នាក់ (៩,៥%) ឆ្លើយថាភ្លៀងទៀងទាត់ខ្លះ និង មិនទៀងទាត់ខ្លះ ខណៈចំនួនមេគ្រួសារឆ្លើយថាភ្លៀងធ្លាក់ទៀងទាត់ខ្លះ៦៩ នាក់ (៧,៧%) ប៉ុណ្ណោះ ។

រូបភាព ៣.១៦ ស្ថានភាពទឹកភ្លៀង



## ៣.៤.២ ស្ថានភាពសីតុណ្ហភាព

រូបភាព ៣.១៧ បង្ហាញថាចំនួនមេគ្រួសារ ៦១៤ នាក់ (៦៨,២%) បានឆ្លើយថា សីតុណ្ហភាពមានកម្តៅខ្លាំង ខណៈដែលចំនួនមេគ្រួសារ ២៧៦ នាក់ (៣០,៧%) ឆ្លើយថាសីតុណ្ហភាពមានកម្តៅល្មមអាចទ្រាំទ្របាន ហើយចំនួនមេគ្រួសារ ៥នាក់(០,៦%) ឆ្លើយថា ត្រជាក់ល្មម និង ត្រជាក់ខ្លាំង។

រូបភាព ៣.១៨ ស្ថានភាពសីតុណ្ហភាព



# ជំពូក ៤
# បញ្ហាប្រឈម របកគំហើញ
# ដំណោះស្រាយ និង សន្និដ្ឋាន

## ៤.១ បញ្ហាប្រឈម

នៅក្នុងការអនុវត្តគម្រោងអង្កេតភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០ សម្រាប់តំបន់ខ្ពង់រាបរួមមានខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលបានឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាលកម្ពុជា អង្គភាពក្រុមសង្កេតការណ៍ភពផែនដី ដែលស្ថិតនៅក្រោមវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ បានជួបបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

### ៤.១ .១ សម្ភារៈ និង ឧបករណ៍បច្ចេកទេស

- នៅក្នុងការចុះស្រង់ទិន្នន័យនៅប្រទេសផ្សេងគេប្រើផ្កាយរណប ថតតាមយន្តហោះ និងតាមឧបករណ៍ដែលអាចថតពីលើអាកាសបានដូចជា ដ្រូន ដែលគេនិយមប្រើនាពេលបច្ចុប្បន្ន ។ ដូច្នេះដោយសារតែប្រទេសយើងពុំមានផ្កាយរណប និងឧបករណ៍សម្រាប់ថតរូបភាពតាមអាកាស នៅពេលចុះស្រង់ទិន្នន័យតាមគោលដៅដែលចង់បាន ក្រុមការងាររបស់អង្គភាពក្រុមសង្កេតការភពផែនដីបានប្រើវិធីចុះសម្ភាសន៍តាមមេភូមិ និងមេគ្រួសារតាមរយៈកម្រងសំណួរ ដើម្បីទទួលបានចម្លើយតាមអ្វីពួកគាត់បានកត់សំគាល់ទាក់ទងទៅនឹងបរិស្ថាន គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុជាដើម។ បើទោះបីជា វិធីសាស្ត្រនៃការប្រមូលទិន្នន័យនេះជាវិធីសាស្ត្រចាស់ក៏ពិតមែន តែគេអាចជឿទុកចិត្តបានពី៦០ ទៅ ៧០ភាគរយផងដែរ។
- ខ្វះមធ្យោបាយធ្វើដំណើរដូចជារថយន្ត ដោយសារតែកិច្ចការងារនេះត្រូវចុះសិក្សាស្រាវជ្រាវដល់ទីតាំងតាមបណ្តាខេត្តផ្សេងៗទាក់ទងទៅនឹងការងារបរិស្ថាន គ្រោះមហន្តរាយ និង ការប្រែប្រួលអាកាសធាតុ។
- ខ្វះកុំព្យូទ័រ និងកៅអីសម្រាប់ធ្វើការងារនៅការិយាល័យពុំគ្រប់គ្រាន់ ខណៈដែលមានបន្ទប់ការិយាល័យធ្វើការងាររួចហើយ។
- ទិន្នន័យទី២ ដែលទទួលបានពីស្ថាប័នផ្សេង ពុំមានឆ្នាំដែលផលិតថ្មីៗ។

### ៤.១.២ ទីប្រឹក្សាអន្តរជាតិ និងថវិកា

- ខ្វះទីប្រឹក្សា ឬ អ្នកជំនាញការអន្តរជាតិ ជួយណែនាំបង្ហាត់បង្ហាញអំពីរបៀបធ្វើការងារដោយសារការងារនេះថ្មី ហើយមន្ត្រីដែលចូលរួមកិច្ចការងារនេះពុំទាន់មានបទពិសោធន៍នៅឡើយ។ កន្លងមក អង្គភាពក្រុមសង្កេតការណ៍ភពផែនដីបានស្នើឲ្យប្រទេសអូស្ត្រាលីជួយបង្កើតទិន្នន័យគូប

តាមលិខិតស្នើសុំតាមរយៈស្ថានទូតអូស្ត្រាលីប៉ុន្តែពុំមានការឆ្លើយតបនៅឡើយ។ ប្រទេសចិនកន្លងមកក៏បានសន្យាថានឹងជួយពង្រឹងសមត្ថភាពមន្ត្រីទាក់ទងការងារទាំងនេះ។

- ថវិកាដែលទទួលបានពីរាជរដ្ឋាភិបាលកម្ពុជាសម្រាប់អនុវត្តគម្រោងការងារនេះនៅមានកំណត់នៅឡើយ ដែលអាចប៉ះពាល់ដល់វិសាលភាពនៃការសិក្សាស្រាវជ្រាវឲ្យបានទូលំទូលាយ។ នៅក្នុងបរិការនៃការឆ្លងរាលដាលជំងឺកូវីដ១៩ នេះ រាជរដ្ឋាភិបាលកម្ពុជាបានកាត់ចំណាយ ៥០% គ្រប់ចំណាយចរន្តទាំងអស់នៅតាមស្ថាប័នរដ្ឋ ខណៈដែលគម្រោងត្រូវអនុវត្ត ៥ ខេត្តនៅសល់តែ ៣ ខេត្តប៉ុណ្ណោះ។

## ៤.១.៣ សមត្ថភាពមន្ត្រី

មន្ត្រីដែលចូលរួមការងារនៅក្នុងគម្រោងនេះ មានជំនាញផ្សេងៗ ដែលមិនសមស្របទៅនឹងជំនាញដែលត្រូវអនុវត្តការងារជាក់ស្តែង ប៉ុន្តែពួកគាត់មានឆន្ទៈការងារខ្ពស់ និងបទពិសោធន៍ក្នុងការចុះស្រង់ទិន្នន័យតាមរយៈគម្រោងផ្សេងៗជាយូរមកហើយ។

## ៤.២ របកគំហើញ

តាមរយៈការសិក្សាស្រាវជ្រាវ នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០ នៅតាមខេត្តគោលដៅទាំង ៣គឺ ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង ដែលផ្អែកលើទិន្នន័យទី២ ដែលទទួលបានពីប្រភពផ្សេងៗ និងទិន្នន័យទី១ ដោយការចុះសម្ភាសន៍ផ្ទាល់ដល់ទីតាំងជាក់ស្តែងបានបង្ហាញអំពីរបកគំហើញដូចខាងក្រោម៖

### ៤.២.១ កំណើនប្រជាជន និង ការធ្វើចំណាកស្រុក

កំណើនប្រជាជនមានការកើនឡើងជាលំដាប់នៅទូទាំងប្រទេស រួមទាំងតំបន់ដែលស្ថិតនៅខ្ពង់រាបផងដែរ បើទោះបីទំហំសមាជិកគ្រួសារមានការធ្លាក់ចុះក៏ដោយ លើកលែងតែខេត្តពោធិ៍សាត់ហាក់មានចំនួនច្រើននៅឡើយ។ សមាជិកក្នុងគ្រួសារភេទស្រីបានធ្វើចំណាកស្រុកក្នុងប្រទេសមានចំនួនច្រើនជាងបុរស ប៉ុន្តែនៅក្រៅប្រទេសតិចជាងបុរស។ ចំណាកស្រុកមករាជធានីភ្នំពេញមានចំនួនច្រើនជាងគេក្នុងចំណោមរាជធានីខេត្តទាំង ២៥ ដោយសារមូលហេតុស្វែងរកការងារធ្វើ ហើយចំណាកស្រុកទៅប្រទេសថៃមានចំនួនច្រើនជាងគេក្នុងចំណោមចំណាកស្រុកក្រៅប្រទេស ដើម្បីស្វែងរកការងារធ្វើ ក្នុងចំណោមប្រទេសដែលពលរដ្ឋខ្មែរធ្វើចំណាកស្រុកនៅក្រៅប្រទេស។ ការចូលរួមកម្លាំងពលកម្មនៅក្នុងវិស័យកសិកម្មមានចំនួនច្រើនជាងគេ បន្ទាប់មកសេវាកម្ម និងវិស័យឧស្សាហកម្មមានចំនួនតិចជាងគេ ក្នុងចំណោមការចូលរួមកម្លាំងពលកម្មក្នុងវិស័យទាំង ៣ ខាងលើនេះ។

### ៤.២.២ តំបន់ទីប្រជុំជនមានការកើនឡើង

ចំនួនប្រជាជនដែលរស់នៅតំបន់ទីប្រជុំជនមានការកើនឡើងជាលំដាប់ចាប់តាំងពីឆ្នាំ ១៩៩៨ មកទល់បច្ចុប្បន្ន និងម្យ៉ាងទៀតរាជរដ្ឋាភិបាលកម្ពុជា បានកែប្រែតំបន់រដ្ឋបាលមួយចំនួនស្របតាមការ

អភិវឌ្ឍរបស់ប្រទេស ប៉ុន្តែជាក្តីបារម្ភផងដែរ ទាក់ទងទៅនឹងសន្តិសុខស្បៀង សម្រាប់ប្រទេសកម្ពុជា ដោយសារដីដែលផលិតដំណាំកសិកម្ម និងដាំណាំស្រូវត្រូវបានបង្វែរសង់លំនៅដ្ឋាន និងធ្វើការអភិវឌ្ឍ ផ្សេងៗ និងផលប៉ះពាល់ដល់បរិស្ថានផ្សេងៗ។

### ៤.២.៣ បរិស្ថាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា បញ្ហាប្រមូលសំរាម ការទុកដាក់សំរាម ការប្រើប្រាស់ទឹកស្អាត និងការប្រើប្រាស់បង្គន់អនាម័យរបស់ប្រជាជននៅមានយល់ដឹងជាងមុនបន្តិច។ ផលប៉ះពាល់ដោយសារការប្រើប្រាស់ថ្នាំគីមី និងថ្នាំបាញ់សម្លាប់សត្វល្អិតមានផលប៉ះពាល់ខ្លាំងគួរឲ្យកត់សំគាល់ និងគួរមានវិធានការណ៍ផ្សេងៗសម្រាប់ប្រជាពលរដ្ឋ។

### ៤.២.៤ គ្រោះមហន្តរាយ

គ្រោះមហន្តរាយធម្មជាតិដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត រន្ទះបាញ់ ខ្យល់ព្យុះ និងបាក់ច្រាំងទន្លេ គឺបានកើតឡើងប្រាកដមែន តាមរយៈនៃកាសិក្សានេះ ។ ការទទួលបានប្រភពព័ត៌មានអំពីគ្រោះមហន្តរាយតាមរយៈទូរទស្សន៍មានចំនួនច្រើនជាងគេ បន្ទាប់មកអាជ្ញាធរ និងតាមរយៈទូរស័ព្ទដៃ។ គ្រោះមហន្តរាយគ្រោះរាំងស្ងួតមានផលប៉ះពាល់ខ្លាំងជាងគេ បន្ទាប់មកទឹកជំនន់ ខ្យល់ព្យុះ និងបាក់ច្រាំងទន្លេតាមលំដាប់រៀង បានកើតឡើងក្នុងតំបន់ដែលបានចុះស្រង់ទិន្នន័យ។ ក្នុងគ្រោះមហន្តរាយក៏បានរកឃើញការឆ្លងជំងឺកូវីដ ១៩ គ្រុនឈាម គ្រុនឈឹក ការបាក់រលំអគារ និងគ្រោះអគ្គិភ័យក៏បានកើតឡើងនៅខេត្តផ្សេង តាមរយៈការប្រមូលនៃទិន្នន័យទី២ ក្នុងអំឡុងពេលសិក្សានេះ។

### ៤.២.៥ ការប្រែប្រួលអាកាសធាតុ

បើទោះបី ការអនុវត្តគម្រោងនេះពុំមានឧបករណ៍ទំនើបសម្រាប់ស្រង់ទិន្នន័យតាមរយៈផ្កាយរណប ឬ ដ្រូនពិតមែន តែតាមរយៈការសិក្សាស្រាវជ្រាវនៃប្រភពទិន្នន័យផ្សេងៗ និងការចុះសម្ភាសន៍ស្រង់ទិន្នន័យផ្ទាល់ដល់មូលដ្ឋានជាក់ស្តែងរកឃើញថាៈ

- កំពស់ទឹកមានការថយចុះ
- ភ្លៀងធ្លាក់មិនទៀងទាត់
- សីតុណ្ហភាពមានការប្រែប្រួលជាពិសេសមានកម្តៅខ្លាំងខុសពីប្រក្រតី។

## ៤.៣ ដំណោះស្រាយ

តាមរយៈការលើកឡើងពីបញ្ហាប្រឈម និងរបកគំហើញដែលបានរកឃើញនៅពេលចុះសិក្សាស្រាវជ្រាវតាមរយៈការអនុវត្តគម្រោងការងារនេះ គួរតែមានដំណោះស្រាយ និងវិធានការណ៍មួយចំនួនដូចខាងក្រោម៖

- ពង្រឹងសមត្ថភាពមន្ត្រីឲ្យមានសមត្ថភាពកាន់តែប្រសើរឡើង និង ដោះស្រាយបញ្ហាប្រឈមដែលបានលើកឡើងតាមដែលអាចធ្វើបាន
- បង្កើតការងារក្នុងប្រទេសឲ្យបានច្រើនទាំងការងារកសិកម្ម ឧស្សាហកម្ម និងសេវាកម្មជៀសវាងការធ្វើចំណាកស្រុកពីខេត្តមួយទៅខេត្តមួយ និងទៅក្រៅប្រទេស
- ថែរក្សាឲ្យបាននូវដីដែលមានសក្តានុពលកសិកម្មសម្រាប់ជាសន្តិសុខស្បៀងយូរអង្វែង ដោយសារតែការកើនឡើងតំបន់ទីប្រជុំជន និងការកើនឡើងសំណង់លំនៅដ្ឋាន
- អប់រំប្រជាជនឲ្យស្វែងយល់អំពីការប៉ះពាល់បរិស្ថានឲ្យបានស៊ីជម្រៅ និង រកវិធីសាស្ត្រយ៉ាងណាការពារ ឬកែច្នៃកាកសំណល់រឹង និងរាវដែលបណ្តាលមកពីរោងសិប្បកម្ម និងរោងចក្រ កុំឲ្យប៉ះពាល់សុខភាពដល់បរិស្ថានការរស់នៅរបស់ប្រជាជនទូទៅ
- រៀបចំសិក្សាអំពីប្រព័ន្ធបង្ហូលទឹកកខ្វក់ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ មុនបង្ហូរចូលអាងធម្មជាតិ
- រៀបចំប្រព័ន្ធផ្តល់ព័ត៌មាន ឬ វិធីសាស្ត្របង្ការគ្រោះមហន្តរាយដែលអាចកើតឡើងដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ រន្ទះបាញ់ និងការបាក់ច្រាំងជាដើម
- រៀបចំវិធាណការណ៍បង្កាទឹកទុកពេលរដូវប្រាំង សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ស្រោចដំណាំ និងសម្រាប់តម្រូវការផ្សេងៗ
- អប់រំប្រជាជនឲ្យយល់ដឹងអំពីការការពារជំងឺឆ្លងផ្សេងៗ និងការពារអគ្គីភ័យ ដែលកើតឡើងដោយយថាហេតុ
- ណែនាំប្រជាជនឲ្យស្វែងយល់ពីការការពារនូវការប្រើប្រាស់ថ្នាំគីមី និងថ្នាំសម្លាប់សត្វល្អិត
- រៀបចំវិធីសាស្ត្របង្ការដែលទាក់ទងទៅនឹងការប្រែប្រួលអាសកាសធាតុមានដូចជា សីតុណ្ហភាពមានការកើនឡើងកម្តៅខ្លាំង និងត្រជាក់ខ្លាំងជាដើម។

## ៤.៤ សន្និដ្ឋាន

តាមរយៈលទ្ធផលនៃអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០២០ នៅក្នុងខេត្ត ៣ ដែលស្ថិតនៅក្នុងតំបន់ខ្ពង់រាប ដោយផ្អែកលើសូចនាករទាំងឡាយដែលប្រមូលបានពីប្រភពផ្សេងៗ និងការចុះសម្ភាសន៍ផ្ទាល់ អាចសន្និដ្ឋានបានថា បញ្ហាប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយធម្មជាតិ និងការប្រែប្រួលអាកាសធាតុពិតជាបានកើតឡើងនៅក្នុងតំបន់ដែលស្ថិតនៅក្នុងក្របខណ្ឌនៃធ្វើអង្កេតនេះពិតប្រាកដមែន ដែលត្រូវរៀបចំគោលនយោបាយ និងផែនការសកម្មភាពសម្រាប់មានវិធានការ

បង្ការផ្សេងៗស្របតាមការអភិវឌ្ឍន៍ និងការប្រែប្រួលអាកាសធាតុជាសកល។ នៅក្នុងផ្នែកគ្រោះមហន្តរាយ គឺពុំមានទិន្នន័យអំពីគ្រោះមហន្តរាយអំពីការរញ្ជួយដីដូចប្រទេសផ្សេងទៀតទេ គឺមានតែគ្រោះមហន្តរាយទឹកជំនន់ គ្រោះរាំងស្ងួត រន្ទះបាញ់ ខ្យល់ព្យុះ និងការបាំងច្រាំងទន្លេ ឬ ស្ទឹង ដែលក្នុងនោះគ្រោះមហន្តរាយប៉ះពាល់ដល់គ្រួសារប្រជាជននៅក្នុងតំបន់ខ្ពង់រាបនៃខេត្តទាំង៣គឺ គ្រោះរាំងស្ងួត និងមានទឹកជំនន់ ខណៈដែលគ្រោះមហន្តរាយដូចជាជំងឺឆ្លងកូវីដ១៩ ជំងឺគ្រុនឈាម និងជំងឺគ្រុនឈឺក ការបាក់រលំអគារ និងអគ្គិភ័យក៏បានកើតឡើងនៅក្នុងខេត្តផ្សេងផងដែរ តែមិនបានកើតឡើងក្នុងតំបន់ដែលយើងសិក្សាឡើយ។

សរុបមក លទ្ធផលនេះ បានបង្ហាញអំពីសមិទ្ធិផលថ្មីមួយទៀតលើកទី ២ បន្ទាប់ពីបានធ្វើការវិភាគរបាយការណ៍ឆ្នាំ ២០១៩ មក នៅក្នុងគម្រោងអង្កេតភពផែនដីនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩ កន្លងទៅ ហើយជាទិន្នន័យនេះ ពិតជាមានសារៈប្រយោជន៍យ៉ាងសំខាន់ដល់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការរៀបចំគោលនយោបាយជាតិ និងការធ្វើផែនការ ដែលទាក់ទងនឹងប្រជាសាស្ត្រ បរិស្ថាន គ្រោះមហន្តរាយ ដែលបានកើតឡើង និងការប្រែប្រួលអាកាសធាតុ បន្ថែមពីលើទិន្នន័យពីប្រភពផ្សេងៗទៀតដែលមានស្រាប់។

## ឯកសារយោង


១. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ១៩៩៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០២។

២. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *របាយការណ៍ទូទៅនៃការធ្វើអង្កេតប្រជារាស្ត្រកម្ពុជាចន្លោះជំរឿនឆ្នាំ ២០០៤* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០២។

៣. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០០៩។

៤. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *អង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ របាយចុងក្រោយ* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៣។

៥. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ តួលេខបណ្តោះអាសន្ននៃចំនួនប្រជាជនសរុប* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៣។

៦. វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ៖ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ ២០១៧* វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ២០១៨។

៧. មន្ទីរផែនការរាជធានី ខេត្ត៖ *ទិន្នន័យមូលដ្ឋាន* ២០១៦, ២០១៧ និង ២០១៨, មន្ទីរផែនការរាជធានី ខេត្ត។

៨. គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ៖ *របាយការណ៍ស្តីពីការងារគ្រប់គ្រងគ្រោះមហន្តរាយរយៈពេល ៩ ខែ ឆ្នាំ* ២០២០, គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

៩. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០១៦*,ក្រសួងធនធានទឹក និងឧតុនិយម។

១០. ក្រសួងធនធានទឹក និងឧតុនិយម៖ *របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារ លើវិស័យធនធានទឹក និងឧតុនិយម ក្នុងប្រចាំឆ្នាំ ២០១៧*,ក្រសួងធនធានទឹក និងឧតុនិយម។

១១. ក្រសួងបរិស្ថាន៖ *របាយការណ៍ស្ថានភាពបរិស្ថានលើកទី ៣ ឆ្នាំ ២០១៩,* ក្រសួងបរិស្ថាន។

១២. National Institute of Statistics, Ministry of Planning, *General Population Census of Cambodia 2008, Analysis of the Census Results, Report 12 Population Projection of Cambodia, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.

១៣. National Institute of Statistics, Ministry of Planning, *Reclassification of Urban Areas in Cambodia 2011, Phnom Penh,* National Institute of Statistics, Ministry of Planning 2011.

# ឧបសម្ព័ន្ធ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ
# នៅតំបន់ខ្ពង់រាបក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និង
# ខេត្តបាត់ដំបង សម្រាប់គាំទ្រសកម្មភាពក្រុមសង្កេតការណ៍
# ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០
# ( សម្រាប់មេភូមិ )

## រៀបចំដោយៈ


អង្គភាពក្រុមសង្កេតការភពផែនដី
វិទ្យាស្ថានជាតិស្ថិតិ
ក្រសួងផែនការ

រាជធានីភ្នំពេញ ខែ សីហា ឆ្នាំ ២០២០

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត................................................ ☐☐

ក្រុង/ស្រុក/ខណ្ឌ............................................ ☐☐

ឃុំ/សង្កាត់.................................................... ☐☐

ភូមិ/មណ្ឌល.................................................. ☐☐

ទីប្រជុំជន/ជនបទ........................................... ☐☐

កាលបរិច្ឆេទចុះស្រង់ទិន្នន័យ: ថ្ងៃទី ........ ខែ ........... ឆ្នាំ ២០២០

ឈ្មោះមេភូមិ .......................................ភេទ ........... អាយុ........

លេខទូរស័ព្ទមេភូមិ ...................................

ឈ្មោះមន្ត្រីសម្ភាសន៍ ................................................

**២. ព័ត៌មានអំពីគ្រួសារក្នុងភូមិ៖**

| ល.រ | ប្រភេទទិន្នន័យ | ២០១៩ | ២០២០ |
|---|---|---|---|
| ១ | ចំនួនប្រជាជនសរុប | | |
| ២ | ចំនួនគ្រួសារសរុប | | |
| ៣ | ចំនួនគ្រួសារទទួលបានទឹកស្អាត | | |
| ៤ | ចំនួនគ្រួសារដែលប្រើប្រាស់អគ្គិសនី | | |
| ៥ | ចំនួនគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់ | | |
| ៦ | ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្ម | | |
| ៧ | ចំនួនប្រជាជនធ្វើការក្នុងវិស័យឧស្សាហកម្ម | | |
| ៨ | ចំនួនប្រជាជនធ្វើការក្នុងវិស័យសេវាកម្ម | | |
| ៩ | ចំនួនរោងចក្រសហគ្រាសដែលមានកម្មករចាប់ពី ១៥នាក់ឡើង | | |

**៣. ព័ត៌មានអំពីគ្រោះមហន្តរាយ ៖**

៣.១ តើប្រជាជនក្នុងភូមិបានទទួលព័ត៌មានគ្រោះមហន្តរាយពីប្រភពណាខ្លះ ?

ក. គ្មាន........................................... ☐

ខ. មាន ........................................... ☐

១. តាមរយៈអាជ្ញាធរមូលដ្ឋាន............ ☐

២. តាមរយៈទូរទស្សន៍.....................☐
៣. តាមរយៈវិទ្យុ...............................☐
៤. តាមរយៈការទំនាក់ទំនងទូរសព្ទដៃ..................................☐
៥. តាមរយៈការផ្ញើសារតាមប្រព័ន្ធទូរសព្ទដៃ...........................☐.
៦. តាមការសែត..............................................................☐
៧. តាមប្រភពផ្សេង (បញ្ជាក់)............................................☐

៣.២ តើមានចំនួនសម្ភារៈប៉ុន្មានដែលខូចខាត ដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ ២០១៩ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ "

ក. ចំនួនផ្ទះសម្បែងដែលខូចខាត ☐
ខ. ចំនួនយានយន្តដែលខូចខាតៈ ម៉ូតូ ☐ ឡាន ☐
. គ.ចំនួនសម្ភារៈខូចខាតផ្សេងៗ (បញ្ជាក់).......................................☐

៣.៣ តើមានជនរងគ្រោះដោយសាររន្ទះបាញ់ប៉ុន្មាននាក់ក្នុង ២០១៩ កន្លងមក ? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

៣.៤ តើមានចំនួនគ្រួសារប៉ុន្មានទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០១៩ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

៣.៥ តើមានចំនួនគ្រួសារប៉ុន្មានដែលខ្វះខាតទឹកប្រើប្រាស់ ដោយសារគ្រោះរាំងស្ងួតក្នុងឆ្នាំ ២០១៩ កន្លងមក? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

៣.៦ តើមានចំនួនគ្រួសារប៉ុន្មានដែលធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំងទន្លេ ស្ទឹង ព្រែក ... ក្នុងឆ្នាំ ២០១៩ កន្លងមកដែរ ឬ ទេ? បើគ្មាន សូមចុះលេខសូន្យ " ០ " ☐

## ៤. ផលប៉ះពាល់បរិស្ថានក្នុងភូមិ

៤.១ ចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីកាកសំណល់ សិប្បកម្ម ឬ រោងចក្រ ☐
៤.២ ចំនួនគ្រួសារដែលរងផលប៉ះពាល់ការបង្ហូរទឹកសំអុយ ☐

## ៥. ការប្រែប្រួលអាកាសធាតុ

៥.១ តើតាមការកត់សំគាល់របស់លោកពូអ្នកមីងឃើញថាមានការប្រែប្រួលទាក់ទងនឹងអាកាសធាតុដូចម្តេចដែរ?

| | | | | |
|---|---|---|---|---|
| ក. សីតុណ្ហភាព | ប្រែប្រួល | ☐ | មិនប្រែប្រួល | ☐ |
| ខ. ទឹកភ្លៀង | ទៀងទាត់ | ☐ | មិនទៀងទាត់ | ☐ |
| គ. គ្រោះរាំងស្ងួត | មានរាំងស្ងួត | ☐ | មិនមានរាំងស្ងួត | ☐ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីសំណួរការចុះស្រង់ទិន្នន័យ
# នៅតំបន់ខ្ពង់រាបក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និង
# ខេត្តបាត់ដំបង សម្រាប់គាំទ្រសកម្មភាពក្រុមសង្កេតការណ៍
# ភពផែនដី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០២០
# (សម្រាប់គ្រួសារ)

**រៀបចំដោយ៖**


អង្គភាពក្រុមសង្កេតការភពផែនដី

វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ


រាជធានីភ្នំពេញ ខែ សីហា ឆ្នាំ ២០២០

**១. ព័ត៌មានសម្គាល់៖**

រាជធានី/ខេត្ត..............................................

ក្រុង/ស្រុក/ខណ្ឌ..........................................

ឃុំ/សង្កាត់..................................................

ភូមិ/មណ្ឌល...............................................

ទីប្រជុំ/ជនបទ ...........................................

កាលបរិច្ឆេទចុះស្រង់ទិន្នន័យៈ ថ្ងៃទី ........ ខែ សីហា ឆ្នាំ ២០២០

ឈ្មោះអ្នកតបសម្ភាសន៍ .............................................

លេខទូរស័ព្ទអ្នកតបសម្ភាសន៍ .....................................

ឈ្មោះមន្ត្រីសម្ភាសន៍ .................................................

**២. ព័ត៌មានទូទៅអំពីគ្រួសារ៖**

**២.១ ចំនួនសមាជិកគ្រួសារ (២០២០)**

ឈ្មោះមេគ្រួសារ ....................................... ភេទ .......... អាយុ ...........

| សមាជិក អចិន្ត្រៃយ៍ | | | សមាជិកចំណាកស្រុក | | | ចំណាកស្រុកក្នុប្រទេស | | | ចំណាកស្រុកក្រៅប្រទេស | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | ប្រុស | ស្រី |
| | | | | | | | | | | | |

**២.១.១ មុខរបបចម្បងរបស់សមាជិកគ្រួសារក្នុងរយៈពេល ១២ ខែ កន្លងមក(២០១៩)**

ក. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យកសិកម្ម (ដាំដំណាំ និងចិញ្ចឹមសត្វ) ៖

ប្រុស ☐ ស្រី ☐ សរុប ☐

ខ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការនេសាទ៖

ប្រុស ☐ ស្រី ☐ សរុប ☐

គ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យឧស្សាហកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. ចំនួនសមាជិកក្នុងគ្រួសារធ្វើការក្នុងវិស័យសេវាកម្ម៖ ប្រុស ☐ ស្រី ☐ សរុប ☐

**២.១.២ សមាជិកគ្រួសារធ្វើការងារក្នុងផ្នែកណាមួយក្នុងរយៈពេល ១២ ខែ កន្លងមក (២០១៩)**

ក.រដ្ឋាភិបាល ប្រុស ☐ ស្រី ☐ សរុប ☐

ខ. អង្គភាពស្វយ័ត ប្រុស ☐ ស្រី ☐ សរុប ☐

គ. ផ្នែកឯកជនខ្មែរ ប្រុស ☐ ស្រី ☐ សរុប ☐

ឃ.ផ្នែកឯកជនបរទេស ប្រុស ☐ ស្រី ☐ សរុប ☐

ង. ស្ថាប័នមិនយកប្រាក់ចំណេញ ប្រុស ☐ ស្រី ☐ សរុប ☐

ច. ផ្នែកគ្រួសារ ប្រុស ☐ ស្រី ☐ សរុប ☐

ឆ.ស្ថានទូត/ស្ថាប័នអន្តរជាតិ និងភ្នាក់ងារអភិវឌ្ឍន៍ និងជំនួយបរទេស

ប្រុស ☐ ស្រី ☐ សរុប ☐

ជ. ផ្សេងៗ..............................ប្រុស ☐ ស្រី ☐ សរុប ☐

**២.១.៣ ចំណាកស្រុកក្នុងប្រទេស (២០២០)**

| ឈ្មោះរាជធានី-ខេត្ត | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្នុងប្រទេស) ចាប់ ៦ ខែឡើង | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |

ក. មូលហេតុចំណាកស្រុកក្នុងប្រទេស

| មូលហេតុ | ចំនួនសមាជិកចំណាកស្រុក (ក្នុងប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| សរុប | | | |

### ២.១.៤ ចំណាកស្រុកក្រៅប្រទេស (២០២០)

| ឈ្មោះប្រទេស | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្រៅប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |

### ក. មូលហេតុចំណាកស្រុកក្រៅប្រទេស

| មូលហេតុ | ចំនួនសមាជិកគ្រួសារចំណាកស្រុក (ក្រៅប្រទេស) | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| សរុប | | | |

### ២.២ មុខរបររបស់សមាជិកគ្រួសារ (២០២០)

| មុខរបរចម្បងៗ | ចំនួនសមាជិកគ្រួសារដែលបានចូលរួម | | |
|---|---|---|---|
| | សរុប | ប្រុស | ស្រី |
| ១. | | | |
| ២. | | | |
| ៣. | | | |
| ៤. | | | |
| ៥. | | | |
| សរុប | | | |

## ៣. ព័ត៌មានបរិស្ថានអំពីគ្រួសារ

១=មាន ២=គ្មាន

| លរ | ប្រភេទប៉ះពាល់បរិស្ថាន | ២០១៩ | ២០២០ |
|---|---|---|---|
| ១ | បង្គន់អនាម័យ | | |
| ២ | សេវាប្រមូលសំរាម | | |
| ៣ | ទីតាំងចោលសំរាម | | |
| ៤ | ទីតាំងទុកដាក់សំរាមនៅក្នុងបរិវេណផ្ទះ | | |
| ៥ | ផលប៉ះពាល់ពីការចោលសំរាម | | |
| ៦ | ផលប៉ះពាល់ពីកាកសំណល់សិប្បកម្ម/រោងចក្រ | | |
| ៧ | ផលប៉ះពាល់បង្ហូរកាកសំណល់ចូលក្នុងទឹក | | |
| ៨ | ផលប៉ះពាល់ថ្នាំបាញ់សម្លាប់សត្វល្អិត | | |
| ៩ | ផលប៉ះពាល់ការប្រើប្រាស់ជីគីមី | | |
| ១០ | កាប់បំផ្លាញព្រៃឈើ | | |
| ១១ | កាប់បំផ្លាញព្រៃលិចទឹក | | |
| ១២ | ផ្សេងៗ (បញ្ជាក់) | | |

## ៤. គ្រោះមហន្តរាយ

៤.១ តើអ្នកបានទទួលព័ត៌មានគ្រោះមហន្តរាយពីប្រភពណាខ្លះ? ☑

ក. គ្មាន...................................... ☐

ខ. មាន.......................................... ☐

១. តាមរយៈអាជ្ញាធរមូលដ្ឋាន............ ☐

២. តាមរយៈទូរទស្សន៍..................... ☐

៣. តាមរយៈវិទ្យុ............................ ☐

៤. តាមរយៈការទំនាក់ទំនងទូរសព្ទដៃ.................................. ☐

៥. តាមរយៈការផ្ញើសារតាមប្រព័ន្ធទូរសព្ទដៃ............................ ☐.

៦. តាមការសែត............................................................... ☐

៧. តាមប្រភពផ្សេង (បញ្ជាក់)........................................... ☐

៤.២ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារខ្យល់ព្យុះ ឬ ខ្យល់កន្ត្រាក់ ដែរ ឬ ទេក្នុងឆ្នាំ២០១៩ កន្លងមក?

បាទ/ចាស ☐ ទេ ☐

- បើបាទ/ចាស សូមបញ្ជាក់ពីប្រភេទនៃការទទួលរងគ្រោះ៖

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតទ្រព្យសម្បត្តិ (កង់, ម៉ូតូ, ឡាន...) ☐

គ. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ឃ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

ង. ផ្សេងៗសូមបញ្ជាក់(...........................................................)

៤.៣ តើសមាជិកគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ២០១៩ កន្លងមក?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៣)*

ក. សមាជិកគ្រួសារទទួលរងរបួស ប្រុស ☐ ស្រី ☐ សរុប ☐

ខ. សមាជិកគ្រួសារទទួលរងគ្រោះដល់ស្លាប់ ប្រុស ☐ ស្រី ☐ សរុប ☐

៤.៤ តើមានសត្វពាហនៈនៅក្នុងគ្រួសារអ្នកដែលទទួលរងគ្រោះដោយសាររន្ទះបាញ់ដែរ ឬ ទេក្នុងឆ្នាំ ២០១៩ កន្លងមក?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៤)*

ក. ចំនួនសត្វពាហនៈស្លាប់ ☐

ខ. ចំនួនសត្វផ្សេងៗដែលស្លាប់សូមបញ្ជាក់(.......................................................) ☐

៤.៥ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារទឹកជំនន់ដែរ ឬ ទេក្នុងឆ្នាំ ២០១៩ កន្លងមក?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៥)*

ក. ខូចខាតផ្ទះសម្បែង ☐

ខ. ខូចខាតដំណាំកសិកម្ម ☐

គ. ប៉ះពាល់ដល់សត្វពាហនៈ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(...........................................................)

៤.៦ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារគ្រោះរាំងស្ងួត ឬ ខ្វះខាតទឹក ដែរ ឬ ទេក្នុងឆ្នាំ ២០១៩ កន្លងមក?

☐ ☐

បាទ/ចាស ទេ

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៤.៦)*

ក. ខូចខាតដំណាំកសិកម្ម ☐

ខ. ប៉ះពាល់ដល់សត្វពាហនៈ ☐

គ. ខ្វះទឹកប្រើប្រាស់ក្នុងគ្រួសារ ☐

ឃ. ផ្សេងៗសូមបញ្ជាក់(..........................................................) ☐

៤.៧ តើគ្រួសារអ្នកធ្លាប់ទទួលរងគ្រោះដោយសារបាក់ច្រាំង ទន្លេ បឹង ស្ទឹង ព្រែក ក្នុងឆ្នាំ ២០១៩ កន្លងមកដែរ ឬ ទេ?

បាទ/ចាស ☐ ទេ ☐

*បើ " ទេ " សូមសួរសំណួរបន្ទាប់ (សំណួរ ៥)*

ក. បាត់បង់ផ្ទះសម្បែង ☐

ខ. បាត់បង់អាយុជីវិត ☐

គ. ផ្សេងៗសូមបញ្ជាក់(..........................................................) ☐

## ៥. ការប្រែប្រួលអាកាសធាតុ

៥.១ តើក្នុងឆ្នាំ ២០១៩ កន្លងមក ស្ថានភាពទឹកភ្លៀងយ៉ាងដូចម្ដេចដែរនៅក្នុងភូមិ?

ក. ទៀងទាត់ ☐

ខ. មិនទៀងទាត់ ☐

គ. ទៀងទាត់ខ្លះ មិនទៀងទាត់ខ្លះ ☐

៥.២ តើសីតុណ្ហភាពក្នុងឆ្នាំ ២០១៩ កន្លងមក មានលក្ខណៈយ៉ាងដូចម្ដេចដែរនៅក្នុងភូមិ?

ក. ក្ដៅខ្លាំង ☐

ខ. ត្រជាក់ខ្លាំង ☐

គ. ក្ដៅល្មម ☐

ឃ. ត្រជាក់ល្មម ☐



The Phnom Penh Post
DEPARTURE



